លេខ / No:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 30-Mar-2017, 10:05
CMS/CFO: Phok Chanthan

**លេខសំណុំរឿង ៖ ០០៣/០៧-០៩-០៩/អ.វ.ត.ក.-ក.ស.ច.ស.**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ២០១៧**

ភាសា ៖ **អង់គ្លេស [ច្បាប់ដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

# ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬ រដ្ឋនោះ

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>មេធាវីការពារក្តី មាស មុត</u>**

អាង ឧត្តម
Michael G. KARNAVAS

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

# I. ប្រវត្តិនីតិវិធី

1. ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះ ត្រូវបានចុះកំណត់ហេតុកាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៤ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

2. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ យើងបានអញ្ជើញភាគីនានានៃសំណុំរឿង០០៣ និងសំណុំរឿង០០៤ ព្រមទាំង*អ្នកមិនមែនជាភាគីជារឿងក្តី* ឲ្យដាក់សារណាអំពីបញ្ហាថាតើ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមាននៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយ ប្រឆាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន អាចចាត់ទុកថាជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិល សម្រាប់គោលបំណងនៃមាត្រា ៥ របស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬទេ (“បញ្ហាចំពោះមុខ”)[1]។ នៅក្នុងការអញ្ជើញនោះ យើងបានជូនដំណឹងដល់ភាគីថា ភាគីទាំងអស់មានពេល ១៥ ថ្ងៃ ដើម្បីដាក់ចម្លើយតបរួមគ្នា សម្រាប់សារណាទាំងអស់ដែល *អ្នកមិនមែនជាភាគីនៃរឿងក្តី* បានដាក់ ហើយថានឹងមិនទទួលយកចម្លើយតបចំពោះសារណារបស់ភាគីដទៃទៀឡើយ[2]។

3. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ មេធាវីការពារក្តី មាស មុត និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សារណារបស់ពួកគេ (“សារណារបស់ មាស មុត" និង "សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ”)[3]។

---

[1] សំណុំរឿង ០០៣-ឯកសារ D191, សេចក្តីអំពាវនាវសុំឲ្យដាក់សារណា ពីភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ និងអ្នកដែលមិនមែនជាភាគី, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ៣, ៦ ដល់៧។

[2] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ 13-14.

[3] សំណុំរឿង ០០៣-ឯកសារ D191/2, សារណារបស់ មាស មុត ស្តីពីសំណួរថាតើ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, (“សារណារបស់ មាស មុត”)។ សំណុំរឿង ០០៣-ឯកសារ D191/1, *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសេចក្តីអំពាវនាវឲ្យដាក់សារណា របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ (“សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ”)។

4. *អ្នកមិនមែនជាភាគីនៃរឿងក្តី* ចំនួន ១១ បានដាក់សារណាស្តីពីបញ្ហាចំពោះមុខ[4]។ មេធាវីការពារក្តី អោ អាន និងមេធាវីការពារក្តី យឹម ទិត្យ ក៏បានដាក់សារណានៅក្នុងសំណុំរឿង ០០៤ ផងដែរ ("សារណារបស់ អោ អាន" និង "សារណារបស់យឹម ទិត្យ")[5]។

---

[4] សំណុំរឿង ០០៣-ឯកសារ D191/3, *សារណារមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ -សាស្ត្រាចារ្យ Ben Saul*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ("សារណារបស់ Ben Saul")។ សំណុំរឿង ០០៣-ឯកសារ D191/4, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ - Catherine Drummond, Philippa Webb និង Dapo Akande*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ Drummond, Webb, and Akande")។ សំណុំរឿង ០០៣-ឯកសារ D191/5, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ - TRIAL (Track Impunity Always)*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ TRIAL")។ សំណុំរឿង ០០៣-ឯកសារ D191/6, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី របស់សាស្ត្រាចារ្យ Robinson, DeGuzman, Jalloh និង Cryer ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់សំណុំរឿង ០០៣ និងសំណុំរឿង ០០៤,* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ Robinson, DeGuzman, Jalloh និង Cryer Brief")។ សំណុំរឿង ០០៣-ឯកសារ D191/7, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ - Ido Rosenzweig*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ("សារណារបស់ Ido Rosenzweig")។ សំណុំរឿង ០០៣-ឯកសារ D191/8, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ - បណ្ឌិត Joanna Nicholson*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ Joanna Nicholson")។ សំណុំរឿង ០០៣-ឯកសារ D191/9, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ -សាស្ត្រាចារ្យ Nicholas Tsagourias*, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ Nicholas Tsagourias")។ សំណុំរឿង ០០៣-ឯកសារ D191/10, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ - Oliver Windridge*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ Oliver Windridge")។ សំណុំរឿង ០០៣-ឯកសារ D191/11, *សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ដែលដាក់ដោយបណ្ឌិត Williams និង Grey ជាការឆ្លើយតបចំពោះការអំពាវនាវ សុំឱ្យដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦,* ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦, ("សារណារបស់ Williams និង Grey")។ សំណុំរឿង ០០៣-ឯកសារ D191/12, *សារណាមិនមែនជាភាគី ដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ នឹងច្បាប់ប្រៀបធៀប មហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យ Baltimore ស្តីពីនីត្យានុកូលភាពនៃការដាក់គោលដៅ វាយប្រហារយោធាខ្លួនឯង,* ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់សាកលវិទ្យាល័យ Baltimore")។ សំណុំរឿង ០០៣-ឯកសារ D191/13, ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្ស នៃសាកលវិទ្យាល័យ *Queen's University Belfast ទៅនឹង "ការអំពាវនាវឱ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និង០០៤ នឹងការអំពាវនាវឱ្យដាក់សារណារបស់អ្នក ដែលមិនមែនជាគូភាគីនៃរឿងក្តី" របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអ.វ.ត.ក,* ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់សាកលវិទ្យាល័យ Queen's")។

5. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្ដី មាស មុត បានស្នើដល់សហចៅក្រមស៊ើបអង្កេត សុំការអនុញ្ញាតដាក់ចម្លើយតបរួមចំនួន ១៥ ទំព័រ ចំពោះសារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្ដី*[6]។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៦ យើងបានអនុញ្ញាតលើសំណើនោះ[7]។

6. នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ មេធាវីការពារក្ដី មាស មុត និង យឹម ទិត្យ បានដាក់ចម្លើយតបចំពោះសារណាដែល*អ្នកមិនមែនជាភាគីនៃរឿងក្ដី* បានដាក់[8]។

## II. សេចក្ដីសង្ខេបសារណា

7. សហព្រះរាជអាជ្ញាអន្តរជាតិ និង*អ្នកមិនមែនជាភាគីនៃរឿងក្ដី*, ការជំនុំជម្រះ, Robinson, DeGuzman, Jalloh និង Cryer; Ido Rosenzweig; Williams និង Grey; សាកលវិទ្យាល័យ Baltimore; និងសាកលវិទ្យាល័យ Queen's University of Belfast បានលើកឡើងទាំង

[5] សំណុំរឿង ០០៤-ឯកសារ D306/3, *សារណារបស់ អោ អាន ស្ដីពីបញ្ហាថាតើ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬយ៉ាងណា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩*, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ អោ អាន")។ សំណុំរឿង ០០៤-ឯកសារ D306/1, *សារណារបស់ យឹម ទិត្យ ស្ដីពីការបកស្រាយពាក្យស័ព្ទ "ប្រជាជនស៊ីវិល" តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក,* ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦, ("សារណារបស់ យឹម ទិត្យ")។

[6] សំណុំរឿង ០០៣-ឯកសារ D191/14, សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់ចម្លើយរួមចំនួន ១៥ ទំព័រ តបទៅនឹងសារណារបស់អ្នកដែលមិនមែនជាគូភាគី លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់ អាចជាការវាយប្រហារដែលសំដៅទៅលើ ប្រជាជនស៊ីវិលឬយ៉ាងណា, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦។

[7] សំណុំរឿង ០០៣-ឯកសារ D191/15, *សេចក្ដីជូនដំណឹងអំពីការបន្ថែម ចំនួនកំណត់នៃទំព័រដើម្បីឆ្លើយតប សារណារបស់អ្នកដែលមិនមែនជាភាគី,* ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៦។

[8] សំណុំរឿង ០០៣-ឯកសារ D191/17, ចម្លើយរួមរបស់ មាស មុត តបនឹងសារណារបស់ អ្នកដែលមិនមែនជាភាគី លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើ ប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ , ("ចម្លើយតបរបស់ មាស មុត")។ សំណុំរឿង ០០៤-ឯកសារ D306/16, *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសារណាដែលបានដាក់ជូនដោយ អ្នកមិនមែនជាភាគីអនុលោមតាមឯកសារ D306*, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ , ("ចម្លើយតបរបស់ យឹម ទិត្យ")។

អស់គ្នាថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនៅជាធរមានចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការ ប្រឆាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន អាចចាត់ទុកថាជា ការវាយប្រហារសំដៅទៅលើប្រជាជនស៊ីវិល[9]។ ផ្ទុយទៅវិញ មេធាវីការពារក្តី មាស មុត មេធាវីការពារក្តី អោ អាន និងមេធាវីការពារក្តី យឹម ទិត្យ បានលើកឡើងថា កងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋមួយ មិនអាចជាគោលដៅតែមួយគត់សម្រាប់គោលបំណងនៃលក្ខខណ្ឌទូទៅ ទោះបីជានៅក្នុងពេលសន្តិភាព ឬនៅពេលមានជម្លោះប្រដាប់អាវុធនោះទេ[10]។ អ្នកមិនមែនជាភាគីនៃរឿងក្តីដែលនៅសល់ បានបង្ហាញពីគោលជំហរដែលនៅចន្លោះក្រុមទាំងពីរនេះ។ Ben Saul, Joanna Nicholson, និង Oliver Windridge បានលើកឡើងថា ទាល់តែនៅពេលមានសន្តិភាព ទើបសមាជិកនៃកងកម្លាំងប្រដាប់អាវុធអាចជាគោលដៅតែមួយនៃការវាយប្រហារ ដែលបំពេញបានតាមលក្ខខណ្ឌទូទៅនៃការវាយប្រហារប្រឆាំងជនស៊ីវិល[11]។ ចំណែក Catherine Drummond, Philippa Webb, and Dapo Akande បានលើកឡើងថា មានតែក្នុងករណីដែលឧក្រិដ្ឋកម្មជាមូលដ្ឋានជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ទើបការវាយប្រហារលើកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬអង្គការនោះ អាចចាត់ទុកថាជាការវាយប្រហារលើប្រជាជនស៊ីវិល[12]។

8. សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកមិនមែនជាភាគីនៃរឿងក្តីជាច្រើន បានពឹងផ្អែកទៅលើមូលដ្ឋានសំខាន់ថា គោលដៅ និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គាំទ្រដល់

---

[9] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៤, ១៣។ សារណារបស់ TRIAL, កថាខណ្ឌ ២១។ សារណារបស់ Robinson, DeGuzman, Jalloh និង Cryer Brief, កថាខណ្ឌ ៣។ *សារណារបស់* Ido Rosenzweig, ទំព័រ ៦។ សារណារបស់ Nicholas Tsagourias,កថាខណ្ឌ ២៥ ដល់២៦។ សារណារបស់ Williams និង Grey, កថាខណ្ឌ ៣, ២៨។ សារណារបស់សាកលវិទ្យាល័យ Baltimore, កថាខណ្ឌ ២៣។ សារណារបស់សាកលវិទ្យាល័យ Queen's, កថាខណ្ឌ ២, ១៦, ១៨។

[10] សារណារបស់ មាស មុត, កថាខណ្ឌ ២៤។ ចម្លើយតបរបស់ មាស មុត, ទំព័រ ១។ សារណារបស់ អោ អាន, កថាខណ្ឌ ២, ៤៤។ សារណារបស់ យឹម ទិត្យ, ERN 01240541, ទំព័រ ១, កថាខណ្ឌ ៣៨។

[11] សារណារបស់ Ben Saul, កថាខណ្ឌ ២៤។ សារណារបស់ Joanna Nicholson, ទំព័រ ១, ៥ ដល់៦។ សារណារបស់ Oliver Windridge, កថាខណ្ឌ ២១។

[12] សារណារបស់ Drummond, Webb, និង Akande, កថាខណ្ឌ ១, ២២។

គោលជំហររបស់ពួកគាត់[13]។ មេធាវីការពារក្តី មាស មុត និងមេធាវីការពារក្តី អោ អាន បានជំទាស់ថា គោលជំហររបស់ពួកគាត់ត្រូវបានគាំទ្រដោយគោលដៅ និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្ស បើទោះបីជាបកស្រាយផ្សេងគ្នាក៏ដោយ[14]។ ជាឧទាហរណ៍ មេធាវីការពារក្តី មាស មុត បានបកស្រាយគោលបំណងនេះក្នុងន័យចង្អៀត ដោយបានលើកទឡ្ហីករណ៍ថា គោលបំណងជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើម្បីបំពេញចន្លោះប្រហោងដែលច្បាប់មនុស្សធម៌អន្តរជាតិមិនបានគ្រប់ដណ្តប់លើ ដូចជា ការការពារជនស៊ីវិលពីការវាយប្រហារដោយរដ្ឋាភិបាលផ្ទាល់របស់ខ្លួន[15] ចំណែក Ben Saul បានបកស្រាយពីគោលបំណងក្នុងលក្ខណៈទូលាយ ថាជាការការពារ "សិទ្ធិជាសារវន្ត និងសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិប្រឆាំងអំពើហិង្សាជាប្រព័ន្ធ ជាពិសេស បុគ្គលណាដែលគ្មានលទ្ធភាពការពារខ្លួនប្រឆាំងអំណាចរបស់រដ្ឋ"[16]។ មេធាវីការពារក្តី យឹម ទិត្យ បានប្រកាន់យកជំហរផ្សេងមួយ ដោយលើកទឡ្ហីករណ៍ថា ដើម្បីពង្រីកការបកស្រាយពាក្យ “ប្រជាជនស៊ីវិល” ឲ្យគ្របដណ្តប់ផងដែរទៅលើ យោធាផ្ទាល់របស់រដ្ឋនោះ គឺជាការបកស្រាយពីគោលបំណងហួសហេតុទៅលើលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាពាក់ព័ន្ធនោះ[17] ហើយការបកស្រាយឃ្លាគឺមិនតម្រូវឲ្យមានឧបាស្រ័យ ដោយធ្វើការស៊ើបអង្កេតអំពីគោលបំណងដែលបានរៀបចំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ហើយថា សហចៅក្រមស៊ើបអង្កេតមិនចាំបាច់ព្យាយាមកំណត់ "គោលបំណង" នៃការព្រាងច្បាប់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[18]។

---

[13] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៧។ សារណារបស់ Ben Saul, កថាខណ្ឌ ៣(ឃ), ២០, ២៤។ សារណារបស់ Drummond, Webb, និង Akande, កថាខណ្ឌ ១០។ សារណារបស់ TRIAL, កថាខណ្ឌ. 22។ សារណារបស់ Ido Rosenzweig, ទំព័រ ៣, ៦។ សារណារបស់ Nicholas Tsagourias, កថាខណ្ឌ ២០។ សារណារបស់ Oliver Windridge, កថាខណ្ឌ ៨, ១៩។ សារណារបស់ Williams និង Grey, កថាខណ្ឌ ១៥, ២០។ សារណារបស់ សាកលវិទ្យាល័យ Queen’s, កថាខណ្ឌ ៦, ១៨។

[14] សារណារបស់ មាស មុត, កថាខណ្ឌ ១ ដល់២។ សារណារបស់ អោ អាន, កថាខណ្ឌ៣១។

[15] សារណារបស់ មាស មុត, កថាខណ្ឌ ១ ដល់២។

[16] សារណារបស់ Ben Saul, កថាខណ្ឌ ២០។

[17] សារណារបស់ យឹម ទិត្យ, កថាខណ្ឌ ៣៨។

[18] ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១៣ ដល់១៥។

9. សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកមិនមែនជាភាគីនៃរឿងក្តីខ្លះ បានលើកទឡ្ហីករណ៍ផងដែរថា ការមិនបញ្ចូលកងទ័ពផ្ទាល់របស់រដ្ឋ ថាជាគោលដៅដែលមិនអាចអនុញ្ញាតបាននៃការវាយប្រហារ ដែលស្ថិតក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងនាំទៅដល់លទ្ធផលដែលមិនសមស្រប ឬដែលមានបញ្ហា គឺកង្វះការការពារតាមផ្លូវច្បាប់ចំពោះពួកគេនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[19]។ មេធាវីការពារក្តី មាស មុត បានលើកឡើង ក្នុងពេលជំទាស់ចំពោះទឡ្ហីករណ៍នេះថា អាស្រ័យលើកាលៈទេសៈ ច្បាប់ជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការហាមឃាត់អំពើប្រល័យពូជសាសន៍ អាចផ្តល់ការការពារចំពោះទាហានទាំងអស់នេះ ហើយវាមិនមែនថាមិនសមស្របឡើយដែលរដ្ឋចាត់ចែងដោយខ្លួនឯងចំពោះការការពារបែបនេះដល់កងទ័ព[20]។

10. សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកមិនមែនជាភាគីនៃរឿងក្តីខ្លះ ក៏បានលើកទឡ្ហីករណ៍ដែលគាំទ្រដល់ការប្រើប្រាស់វិធីសាស្ត្រកំណត់គោលដៅដំណើរការបាន ឬស្របច្បាប់ ចំពោះនិយមន័យនៃជនស៊ីវិល។ ទឡ្ហីករណ៍នេះ ដែលត្រូវបានទាញចេញពីគោលការណ៍នៃភាពខុសគ្នាពីច្បាប់មនុស្សធម៌អន្តរជាតិ បានបញ្ជាក់ថា ជនស៊ីវិលគួរត្រូវបានកំណត់ថាជាជនទាំងឡាយណាដែលមិនអាចត្រូវបានកំណត់ជាគោលដៅ ដោយស្របច្បាប់ ឬប្រកបដោយនីត្យានុកូលភាព នៅក្នុងជម្លោះប្រដាប់អាវុធ ដោយអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ ដែលរួមទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដែល *បាត់បង់សមត្ថភាពប្រយុទ្ធ* ឬដែលមិនធ្វើសកម្មភាពប្រឆាំងរដ្ឋាភិបាលរបស់ខ្លួន ដែលត្រូវពិចារណាអំពីមុខងារ ឬការគ្មានមុខងាររបស់អ្នកទាំងនោះ នៅក្នុងជម្លោះប្រដាប់អាវុធ នៅក្នុងការកំណត់ពីឋានៈជាជនស៊ីវិលរបស់គាត់[21]។ មេធាវីការពារក្តី មាស មុត ជំទាស់ចំពោះវិធីសាស្ត្រនេះ នៅក្នុងចម្លើយតបរបស់ពួកគាត់ ដោយ

---

[19] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥។ សារណារបស់ Robinson, DeGuzman, Jalloh និង Cryer Brief, កថាខណ្ឌ ២, ២២។ សារណារបស់ Nicholas Tsagourias, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, កថាខណ្ឌ ២២។ សារណារបស់ Oliver Windridge, កថាខណ្ឌ ១៩។ សារណារបស់ Ben Saul, កថាខណ្ឌ ២១, ២៤។

[20] ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ៤ ដល់៥, ២៣។

[21] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៦។ សារណារបស់ Ben Saul, កថាខណ្ឌ ២២។ សារណារបស់ TRIAL, កថាខណ្ឌ ១៤ ដល់២០។ សារណារបស់ Robinson, DeGuzman, Jalloh និង Cryer, កថាខណ្ឌ ២ ដល់ ២២។ សារណារបស់ Ido Rosenzweig, ទំព័រ ៤ ដល់៦។សារណារបស់ Williams និង Grey, កថាខណ្ឌ ៦, ១៥, ១៧។ សារណារបស់សាកលវិទ្យាល័យ Baltimore, ទំព័រ ៤ ដល់៦។

អះអាងថា អ្នកមិនមែនជាភាគីនៃរឿងក្តី មិនគ្រាន់តែបានបកស្រាយខុសទៅលើយុត្តិសាស្ត្រស្តីពីបញ្ហានេះប៉ុណ្ណោះទេ ប៉ុន្តែ គោលការណ៍ច្បាប់មនុស្សធម៌អន្តរជាតិមិនអាចត្រូវបញ្ចូលទាំងស្រុងទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ដោយមិនត្រឹមតែប្រឆាំងគោលដៅមិនស្របច្បាប់តាមច្បាប់មនុស្សធម៌អន្តរជាតិឡើយ[22]។

11. អ្នកមិនមែនជាភាគីនៃរឿងក្តីមួយចំនួនបានប្រកាន់ជំហរថា ការធ្វើទុក្ខបុកម្នេញដែលជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងចំណោមធាតុផ្សំទូទៅ មិនរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវនៃការវាយប្រហារទៅលើប្រជាជនស៊ីវិលឡើយ។ ការបកស្រាយដែលបានស្នើឡើងនេះរួមបញ្ចូលទាំងការការពារតាមផ្លូវច្បាប់ប្រឆាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះកងទ័ពដែលត្រូវបានបោសសម្អាតពីសេវាយោធារបស់ប្រទេសពួកគេផ្ទាល់ ដោយសារតែពូជសាសន៍ ជំនឿសាសនា ទស្សនៈមនោគមន៍វិជ្ជា ឬលក្ខណៈដែលមិនអាចផ្លាស់ប្តូរផ្សេងទៀត[23]។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តី មាស មុត បានបដិសេធការអះអាងនេះ ដោយលើកទឡ្ហីករណ៍ថា (១) គោលការណ៍នៃអធិបតេយ្យភាពតម្រូវថា ការបោសសម្អាតបែបនេះ គឺស្ថិតក្រោមច្បាប់ជាតិ មិនមែនច្បាប់អន្តរជាតិទេ ព្រោះថាបទប្បញ្ញត្តិដែលស្ថិតក្រោមច្បាប់អន្តរជាតិនេះនឹងនាំទៅដល់ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះរដ្ឋ ដែលគ្រាន់តែរារាំងរដ្ឋប្រហារ ឬការបះបោរ[24] ប៉ុណ្ណោះ ហើយថា (២) បទប្បញ្ញត្តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ អ.វ.ត.ក មិនបានញែកដាច់ពីគ្នារវាងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទេ ដែលមានន័យថា លក្ខខណ្ឌទូទៅនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល អនុវត្តចំពោះការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[25]។

12. ទឡ្ហីករណ៍គន្លឹះមួយទៀតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកមិនមែនជាភាគីនៃរឿងក្តីគឺថា ច្បាប់មនុស្សធម៌អន្តរជាតិ ជា *ច្បាប់ពិសេស* ដូច្នេះ ចាំបាច់ត្រូវតែញែកឲ្យដាច់ពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ហេតុដូច្នេះ ពួកគេបានផ្តល់សំអាងហេតុ

---

[22] ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ១៨ ដល់២១។

[23] សារណារបស់ Drummond, Webb, និង Akande, កថាខណ្ឌ ១១ ដល់១១។ សារណារបស់ Williams និង Grey, កថាខណ្ឌ១៦។ សារណារបស់សាកលវិទ្យាល័យ Queen's, កថាខណ្ឌ ៣។

[24] សារណារបស់ មាស មុត, កថាខណ្ឌ ២២ ដល់២៣។

[25] ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ២៣ ដល់២៥។

ថា និយមន័យនៃជនស៊ីវិលដែលប្រើប្រាស់នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ មិនគួរទាញយកមកធ្វើជានិយមន័យនៃជនស៊ីវិលសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ជាពិសេស នៅពេលពិចារណាពីការវាយប្រហារលើកងទ័ពនៅក្នុងពេលសន្តិភាព ក្នុងពេលដែលច្បាប់មនុស្សធម៌អន្តរជាតិមិនអាចអនុវត្តបានទាល់តែសោះនោះ[26]។ នៅក្នុងចម្លើយតបរបស់ពួកគេ មេធាវីការពារក្តី យឹម ទិត្យ បានលើកទឡ្ហីករណ៍ប្រហែលគ្នាថា ច្បាប់មនុស្សធម៌អន្តរជាតិ គឺជា *ច្បាប់ពិសេស* ហើយមិនអាចអនុវត្តបាន ក្នុងការកំណត់និយមន័យពីប្រជាជនស៊ីវិលសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[27]។ ទោះជាយ៉ាងនេះក្តី មេធាវីការពារក្តី យឹម ទិត្យ មានការសន្និដ្ឋានផ្សេង គឺថា កងទ័ពត្រូវប្រព្រឹត្តចំពោះពួកគាត់ផ្សេងពីជនស៊ីវិល ទាំងនៅក្នុងពេលសន្តិភាព និងក្នុងពេលមានជម្លោះប្រដាប់អាវុធ ឧទាហរណ៍ ពួកគាត់ត្រូវអនុវត្តច្បាប់ព្រហ្មទណ្ឌយោធា មិនមែនច្បាប់ព្រហ្មទណ្ឌធម្មតាទេ[28]។ ប្រហែលគ្នានេះ មេធាវីការពារក្តី មាស មុត បានទទួលស្គាល់ពីឋានៈជា *ច្បាប់ពិសេស* របស់ច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា កងទ័ព និងជនស៊ីវិល ត្រូវទទួលបានបទដ្ឋាន និងការការពារខុសគ្នា ទោះបីជានៅក្នុងពេលសង្គ្រាម ឬពេលសន្តិភាពក៏ដោយ ហើយថា អំពើរបស់របបមួយប្រឆាំងចំពោះកងទ័ពខ្លួនឯងក្នុងពេលសន្តិភាព នឹងត្រូវដោះស្រាយដោយច្បាប់ជាតិ ឬត្រូវជំនុំជម្រះជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាស្រ័យលើកាលៈទេសៈ គឺមិនមែនជំនុំជម្រះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[29]។ លើសពីនេះទៀត ទាំងមេធាវីការពារក្តី មាស មុត និងមេធាវីការពារក្តី យឹម ទិត្យ បានលើកទឡ្ហីករណ៍ថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ គឺជាច្បាប់ខុសគ្នា ដែលមិនត្រូវបញ្ចូលគ្នាឡើយ ព្រោះច្បាប់ព្រហ្មទណ្ឌ

---

[26] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៥ ដល់៧។ សារណារបស់ Ben Saul, កថាខណ្ឌ ៧, ៩, ១១។ សារណារបស់ Drummond, Webb, និង Akande, កថាខណ្ឌ១៨។ សារណារបស់ TRIAL, កថាខណ្ឌ ៧ ដល់១០។ សារណារបស់ Joanna Nicholson, ទំព័រ ១។ សារណារបស់ Nicholas Tsagourias, កថាខណ្ឌ ១៨ ដល់២១។ សារណារបស់ Oliver Windridge, កថាខណ្ឌ ១៦, ២០។ សារណារបស់ Williams និង Grey , កថាខណ្ឌ ១៨ ដល់២០។

[27] ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១៩ ដល់២០។

[28] ដូចដើងទំព័រខាងលើ, កថាខណ្ឌ ២១ ដល់៣១។

[29] សារណារបស់ មាស មុត, កថាខណ្ឌ ១៧, ២៣។

អន្តរជាតិផ្តន្ទាទោសលើបុគ្គលដែលទទួលខុសត្រូវលើការរំលោភបំពានច្បាប់ ចំណែកច្បាប់សិទ្ធិមនុស្សអន្តរជាតិផ្តន្ទាទោសរដ្ឋដែលត្រូវទទួលខុសត្រូវ[30]។

13. មេធាវីការពារក្តី មាស មុត និងមេធាវីការពារក្តី អោ អាន បានលើកឡើងដូចគ្នាថា គោលការណ៍នីត្យានុកូលភាព និងគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវថា រាល់វិមតិសង្ស័យ ឬភាពមិនច្បាស់លាស់ណាមួយនៅក្នុងការបកស្រាយពាក្យជនស៊ីវិល គួរត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់ជនត្រូវចោទ[31]។ ទោះជាយ៉ាងណាក្តី Ben Saul បានលើកឡើងថា និយមន័យទូលាយរបស់ពាក្យជនស៊ីវិល ដែលអនុញ្ញាតឱ្យមានការរួមបញ្ចូលកងទ័ពផ្ទាល់របស់រដ្ឋនោះ នឹងមិនរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាពឡើយ បើតាមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ ព្រោះថា គោលការណ៍នេះមិនហាមឃាត់ អ.វ.ត.ក មិនឱ្យបកស្រាយ ឬបញ្ជាក់បទៅលើច្បាប់ឡើយ ហើយនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អាចប្រមើលមើលឃើញថា សមាជិកដែលមិនអាចការពារខ្លួន នៃយោធារបស់រដ្ឋដែលមិនត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិនោះ អាចត្រូវបញ្ចូលជាផ្នែកមួយនៃប្រជាជនស៊ីវិលដែរ[32]។

14. ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ មេធាវីការពារក្តី មាស មុត មេធាវីការពារក្តី អោ អាន និងអ្នកមិនមែនជាភាគីនៃរឿងក្តីជាច្រើនទៀត បានឯកភាពគ្នាថា កងទ័ពអាចជាជនរងគ្រោះជាបុគ្គលនៃការវាយប្រហារដែលអាចកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើការវាយប្រហារនោះត្រូវបានធ្វើសំដៅជារួមទៅលើប្រជាជនស៊ីវិល[33]។ ប៉ុន្តែមេធាវីការពារក្តី មាស មុត និងមេធាវីការពារក្តី អោ អាន បានលើកឡើងថា ចំណុចនេះមិនពាក់ព័ន្ធទៅនឹង

---

[30] ដូចជើងទំព័រខាងលើ, កថាខណ្ឌ ២២។ ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១៦ ដល់១៨។

[31] សារណារបស់ មាស មុត, កថាខណ្ឌ២៥។ ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ១, ៣១។ សារណារបស់ អោ អាន , កថាខណ្ឌ ៤១ ដល់៤៣។

[32] សារណារបស់ Ben Saul, កថាខណ្ឌ ២២។

[33] សារណារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ១៤។ ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ២៦។ សារណារបស់ អោ អាន, កថាខណ្ឌ៤០។ សារណារបស់ Ben Saul, កថាខណ្ឌ ២៣។ សារណារបស់ Joanna Nicholson, ទំព័រ ២។ សារណារបស់ Nicholas Tsagourias, កថាខណ្ឌ ២៣។ សារណារបស់ Oliver Windridge, កថាខណ្ឌ១៦។ សារណារបស់ Williams និង Grey, កថាខណ្ឌ ២០, ២៤ ដល់២៦, ២៩។

បញ្ហានៅចំពោះមុខទេ ព្រោះថា ទោះបីជាទាហាន ដែលរួមទាំងទាហាន*បាត់បង់សមត្ថភាពប្រយុទ្ធ* អាចជាជនរងគ្រោះ ឬមិនអាចក៏ដោយនោះ នេះមិនមែនជាកត្តាកំណត់ថាតើ ទាហានអាចចាត់ទុកជាជនស៊ីវិលឬអត់នោះទេ[34]។

## III. ការពិភាក្សា

### ក. សេចក្តីផ្តើម

15. នៅក្នុងការគោរពតាមគោលការណ៍នីត្យានុកូលភាព អ.វ.ត.ក មានយុត្តិធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានអត្ថិភាព ហើយត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[35]។ អង្គជំនុំជម្រះច្រើននៃ អ.វ.ត.ក បានសម្រេចថា និយមន័យដែលមានចែងនៅក្នុងមាត្រា ៥នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ស៊ីសង្វាក់គ្នា និងបានឆ្លុះបញ្ចាំងពីនិយមន័យនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[36]។ ដើម្បីដោះស្រាយបញ្ហាចំពោះមុខ ជាការចាំបាច់ត្រូវបញ្ជាក់ថាតើ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ លក្ខខណ្ឌតម្រូវនៃការវាយប្រហារប្រឆាំងប្រជាជនស៊ីវិលរួមបញ្ចូលការវាយប្រហារដោយរដ្ឋ ឬអង្គការ ប្រឆាំងកងកម្លាំងផ្ទាល់របស់ខ្លួនដែរឬទេ។ ការវិភាគខាងក្រោមនឹងពិនិត្យទៅលើគោលការណ៍នីត្យានុកូលភាព និងផលប៉ះពាល់នៃគោលការណ៍នេះ ព្រមទាំងលក្ខណវិនិច្ឆ័យដែលអាចអនុវត្តបានសម្រាប់ការបកស្រាយលើច្បាប់ព្រហ្មទណ្ឌ។ ការវិភាគនេះនឹងកំណត់ពីហេតុផលនៃការដាក់បញ្ចូលច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងពិនិត្យទៅលើភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និងទស្សនៈច្បាប់ដែលពាក់ព័ន្ធ នៅមុនឆ្នាំ១៩៧៥។ ចុងក្រោយ នឹងមានការបកស្រាយតាមយុត្តិសាស្ត្ររបស់ពាក្យប្រជាជនស៊ីវិល នៅក្រោយអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយនឹងមានកំណត់អំពីកម្រិតដែលអាចផ្តល់ព័ត៌មានទៅដល់ការពិភាក្សាលើចំណុចនេះ។

---

[34] ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ២៦។ សារណារបស់ អោ អាន, កថាខណ្ឌ៤០។

[35] សំណុំរឿង ០០១-ឯកសារ F28, សាលដីកាក្នុងសំណុំរឿង ០០១, ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, កថាខណ្ឌ ៩៩, (“សាលដីកាសំណុំរឿង ឌុច”)។

[36] *សូមមើល* សំណុំរឿង ០០២-ឯកសារ E313, សាលក្រមសំណុំរឿង ០០២/០១, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ១៧៦, (“សាលក្រមសំណុំរឿង ០០២/០១”), *ដកស្រង់* សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ១០០ ដល់១០៤។

## ខ. គោលការណ៍នីត្យានុកូលភាព

### *១. នីត្យានុកូលភាព*

16. គោលការណ៍នីត្យានុកូលភាព គឺជាគោលការណ៍ជាសារវន្តនៃច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក បានចែងថា "មិនមាននរណាម្នាក់ត្រូវមានពិរុទ្ធភាព ចំពោះបទល្មើសព្រហ្មទណ្ឌ ផ្អែកលើអំពើសកម្ម ឬអំពើអកម្ម ដែលមិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ តាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត"ឡើយ។ គោលការណ៍នេះត្រូវបានបញ្ចូលរួចហើយនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ហើយបានក្លាយជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៧ របស់កម្ពុជា[37]។ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គោលការណ៍តម្រូវថា ទម្រង់នៃការទទួលខុសត្រូវ និងបទល្មើសដែលបានចោទប្រកាន់ ត្រូវមានអត្ថិភាពតាមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ និយមន័យនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដោយសារតែមានអត្ថិភាពនៅពេលនោះ ចាំបាច់ត្រូវតែអាចអនុវត្តបាន លើកលែងតែមានការចែងថា ការដកបទល្មើសទាំងស្រុង ឬដោយផ្នែក បានកើតមាន តាមវិធាននៃច្បាប់ដាក់ទោសស្រាលជាងមុន[38]។

---

[37] អត្ថបទជាភាសាបារាំងនៃមាត្រា ៦ នៃក្រុមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានចែងថា *"La Loi penale est sans effet retroactif. Aucune infraction ne peut être reprimée par l'application de peines qui n'étaient pas prononcées par la Loi auកថាខណ្ឌvant qu'elle fut commise [...]"*។ *សូមមើលផងដែរ* មាត្រា ៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៧។

[38] *សូមមើល* សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ១៦។ ទោះបីជាអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស"), ដែលខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះ មិនអាចអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក ក៏ដោយ តែយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ("តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស") មានលក្ខណៈផ្តល់សំអាងហេតុលម្អិតជាង គណៈកម្មការសិទ្ធិមនុស្សដែលជាស្ថាប័ន គ្រប់គ្រងលើការអនុវត្ត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ លើសពីនេះទៀតនោះ អត្ថបទនៃមាត្រា ៧(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺមានលក្ខណៈដូចគ្នាបេះបិទ ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានបន្ថែមនូវបទប្បញ្ញត្តិថែម អំពីការអាចអនុវត្តបានក្រោយហេតុការណ៍ នៃ *ច្បាប់ដាក់ទោសស្រាលជាងមុន* *(lex mitior)* នៅក្នុងបញ្ហាព្រហ្មទណ្ឌ (ទោះជាយ៉ាងនេះក្តីតុលាការ

## *២. ការអាចដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលមើលដឹងថាជាបទល្មើស*

17. ជាលក្ខខណ្ឌតម្រូវបន្ថែម ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចាំបាច់ត្រូវតែអាចដឹងថាមានច្បាប់ចែង ហើយលទ្ធភាពនៃការផ្តន្ទាទោស គឺអាចប្រមើលមើលដឹងបានគ្រប់គ្រាន់ដោយជនត្រូវចោទ នៅពេលវេលាពាក់ព័ន្ធនោះ[39]។ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនេះ បទល្មើសព្រហ្មទណ្ឌចាំបាច់ត្រូវតែមានចែងច្បាស់លាស់នៅក្នុងច្បាប់ (ទោះបីជាវិជ្ជមាន ឬទំនៀមទម្លាប់) ដូច្នេះហើយត្រូវអនុញ្ញាតឲ្យបុគ្គលម្នាក់អាចដឹងតាមរយៈពាក្យពេចន៍ និងក្នុងករណីចាំបាច់ មានជំនួយពីការបកស្រាយដោយតុលាការ ឬដោយការស្វែងរកសេវាប្រឹក្សាច្បាប់[40] អំពីថាតើ អំពើសកម្ម ឬអំពើអកម្មអ្វីដែលធ្វើឲ្យគាត់ទទួលខុសត្រូវព្រហ្មទណ្ឌនោះ[41]។ គោលការណ៍ចាំបាច់ត្រូវបកស្រាយក្នុងលក្ខណៈមួយដែលអាចផ្តល់ការការពារប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មតាមអំពើចិត្ត[42]។ ការអាចប្រមើលមើលដឹងថាជាបទល្មើសមិន

---

អឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានសម្រេចនាពេលកន្លងមក ដែលបានផ្លាស់ប្តូរគោលជំហរ ដែលបានបង្ហាញដោយតុលាការដដែលនេះនៅក្នុងឆ្នាំ ១៩៧៨ ថាគោលការណ៍*ច្បាប់ដាក់ទោសស្រាលជាងមុន (lex mitior)* គឺជាផ្នែកនៃមាត្រា ៧(១), *សូមមើល* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *Scoppola តទល់នឹង ប្រទេសអ៊ីតាលី (No. 2)*, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩, កថាខណ្ឌ ១០៣ ដល់១០៩។ ហេតុដូច្នេះខ្ញុំនឹងស្វែងរកគោលការណ៍ណែនាំ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស លើគោលការណ៍នីត្យានុកូលភាព ប្រសិនបើចាំបាច់សម្រាប់ដំណោះស្រាយលើបញ្ហាចំពោះមុខ។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សបានបញ្ជាក់ថា នីត្យានុកូលភាពតម្រូវថា នៅពេលដែលជនជាប់ចោទបានប្រព្រឹត្តអំពើមួយ ដែលនាំទៅដល់ការជំនុំជម្រះលើរូបគាត់ និងការផ្តន្ទាទោសគាត់នោះ ចាំបាច់ត្រូវតែមានបទប្បញ្ញត្តិច្បាប់មួយ ដែលចែងថាអំពើនោះអាចត្រូវដាក់ទណ្ឌកម្មបាន, *សូមមើល* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *Coëme និងអ្នកដទៃទៀត តទល់នឹង ប្រទេសបែលហ្ស៊ិក,* ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០, កថាខណ្ឌ ១៤៥។

[39] *សូមមើល* សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ១៦។សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ៩៦, ១០០ ដល់ ១០៤។

[40] តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *Chauvy និងអ្នកដទៃទៀត តទល់នឹងប្រទេសបារាំង,* ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤, កថាខណ្ឌ ៤៤។

[41] តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *S.W. តទល់នឹង ចក្រភពអង់គ្លេស,* ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៥។

[42] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៣៤។

តម្រូវឲ្យមានភាពប្រាកដប្រជាច្បាស់លាស់អំពីលទ្ធភាពនៃការចោទប្រកាន់ព្រហ្មទណ្ឌឡើយ[43] ។ ត្រឹមតែការអាចប្រមើលមើលដឹងថាជាបទល្មើស *ដោយសមហេតុផល និងគ្រប់គ្រាន់* គឺគ្រប់គ្រាន់ទៅហើយ[44]។

*៣. ការបកស្រាយពីបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌ*

18. នីត្យានុកូលភាពមិនបានរារាំងចៅក្រមមិនឲ្យបកស្រាយ និងបញ្ជាក់អំពីបទប្បញ្ញត្តិច្បាប់ឡើយ[45]។ ទោះបីជានិយាមព្រហ្មទណ្ឌចាំបាច់ត្រូវតែរៀបចំឡើងដោយច្បាស់លាស់ ដូចជាបទប្បញ្ញត្តិច្បាប់ទាំងអស់ដែរក៏ដោយ តែនិយាមព្រហ្មទណ្ឌត្រូវបានតាក់តែងឡើងក្នុងលក្ខណៈទូទៅ និងមិនជាក់លាក់។ ដូច្នេះ ការបកស្រាយដោយតុលាការក្នុងកម្រិតណាមួយជារឿងមិនអាចជៀសបានទេ[46]។ ដូចដែលបានបញ្ជាក់ដោយមានភាពស៊ីសង្វាក់កន្លងមកនៅក្នុងសេចក្ដីសម្រេចជាច្រើនរបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស តែងតែមានតម្រូវការក្នុងការពន្យល់ទៅលើចំណុចដែលមិនច្បាស់ និងក្នុងការសម្របទៅតាមកាលៈទេសៈដែលមានការផ្លាស់ប្ដូរ[47] ហើយនីត្យានុកូលភាព *"មិនអាចបកស្រាយថាជាការដាក់ឲ្យនៅក្រៅច្បាប់នូវការបញ្ជាក់ជាបន្តបន្ទាប់លើវិធាននៃការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈការបកស្រាយតាមផ្លូវតុលាការពីរឿងក្ដីមួយទៅរឿងក្ដីមួយទៀត ឲ្យតែបើការវិវត្តន៍ដែលជាលទ្ធផល មានភាពស៊ីសង្វាក់គ្នាជាមួយនឹងធាតុសំខាន់នៃបទល្មើស ហើយអាចត្រូវប្រមើលមើលឃើញដោយសមហេតុផល"*[48]

---

[43] *សូមមើល* សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ១៦។ សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ៩៦, ១០០ ដល់ ១០៤។ *សូមមើលផងដែរ* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, Scoppola *តទល់នឹង ប្រទេសអ៊ីតាលី (No. 2)*, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩, កថាខណ្ឌ ១០១។

[44] *ដូចជើងទំព័រខាងលើ*

[45] សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ៩៥។

[46] តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, Scoppola *តទល់នឹង ប្រទេសអ៊ីតាលី (No. 2)*, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩, កថាខណ្ឌ ១០០។

[47] *សូមមើលជាឧទាហរណ៍* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, S.W. *តទល់នឹង ចក្រភពអង់គ្លេស*, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៦។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, Kokkinakis *តទល់នឹង* Greece, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣, កថាខណ្ឌ ៤០។

[48] តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, Scoppola *តទល់នឹង ប្រទេសអ៊ីតាលី (No. 2)*, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩, កថាខណ្ឌ ១០១។

។ ចៅក្រម *"អាចមិនបង្កើតច្បាប់ថ្មី ឬបកស្រាយច្បាប់ដែលមានស្រាប់ ឱ្យហួសពីដែនកំណត់សមហេតុផលនៃការបញ្ជាក់ដែលអាចទទួលយកបាន"*[49]។ ទោះជាយ៉ាងនេះក្តី មិនត្រូវបោះបង់ចំណុចសមស្របជាទូទៅដែលថា ការដែលគ្រាន់តែមិនមានយុត្តិសាស្ត្ររបស់តុលាការ មិនមែនជាការហាមឃាត់ចំពោះតុលាការក្នុងការលើកឡើងពីច្បាប់ជាលើកដំបូងនោះឡើយ[50]។

*៤. លក្ខណវិនិច្ឆ័យនៃការបកស្រាយដែលអាចអនុវត្តបាន*

19. មាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា ("អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា") តម្រូវថា សន្ធិសញ្ញាមួយគួរត្រូវបានបកស្រាយដោយស្មោះត្រង់ អនុលោមតាមអត្ថន័យធម្មតាដែលបានផ្តល់ទៅឱ្យពាក្យពេចន៍នៅក្នុងសន្ធិសញ្ញានោះ នៅក្នុងបរិបទរបស់សន្ធិសញ្ញានោះ និងស្របតាមគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញានោះ។ មាត្រា ៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា បានអនុញ្ញាតឱ្យស្វែងរកដំណោះស្រាយនៅក្នុងការងាររៀបចំសន្ធិសញ្ញា និង *"កាលៈទេសៈនៃការបញ្ចប់សន្ធិសញ្ញានោះ"* នៅពេលដែលលក្ខណវិនិច្ឆ័យនៃការបកស្រាយមាត្រា៣១ អាចទុកឱ្យអត្ថន័យមានភាពមិនច្បាស់លាស់ ឬស្រពិចស្រពិល ឬនាំទៅដល់លទ្ធផលមួយដែលមានភាពមិនត្រឹមត្រូវ ឬមិនសមហេតុផលពិតប្រាកដ។ លក្ខណវិនិច្ឆ័យនៃការបកស្រាយទាំងអស់នេះ មានភាពស្មើគ្នាជាអត្ថន័យ បើធៀបទៅនឹងលក្ខណវិនិច្ឆ័យដែលទទួលស្គាល់នៅ អ.វ.ត.ក ដូចជា ពាក្យពេចន៍នៃបទប្បញ្ញត្តិ ទីកន្លែងរបស់វានៅក្នុងក្របខណ្ឌទាំងមូលនៃច្បាប់ គោលដៅ និងគោលបំណងរបស់វា និងតម្រូវការក្នុងការជៀសពីការបកស្រាយដែលនឹងនាំទៅដល់លទ្ធផលដែលមិនត្រឹមត្រូវ[51]។

---

[49] សាលដីកាសំណុំរឿង ឌុច, កថាខណ្ឌ ៩៥, *ដកស្រង់ រដ្ឋអាជ្ញា តទល់នឹង* Ojdanić *និងអ្នកដទៃទៀត*, សំណុំរឿង លេខ IT-99-37-AR72, *សាលដីកាលើការជំទាស់របស់* Dragoljub Ojdanić *ប្រឆាំងយុត្តាធិការលើ សហឧក្រិដ្ឋកម្មរួម*, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ ៣៨។

[50] *សូមមើល* Kenneth S. Gallant, *The Principle of Legality in International and Comparative Criminal Law*, ឆ្នាំ២០០៩, Cambridge University Press, New York, ទំព័រ ៣៦០។

[51] សំណុំរឿង ០០២-ឯកសារE50/3/1/4, *សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទុំរបស់ ខៀវ សំផន លើសំណើសុំដោះលែង*, ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៣១។ សំណុំរឿង ០០២-ឯកសារD427/1/30, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ*, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១, កថាខណ្ឌ ១២២។

20. ស្ថាប័នសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានធ្វើការពិចារណាជាញឹកញាប់ទៅលើគោលដៅ និងគោលបំណងរបស់ច្បាប់ នៅពេលបកស្រាយពីពាក្យសំខាន់ៗ[52]។ ទោះជាយ៉ាងនេះក្តី បទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មិនត្រូវបកស្រាយដោយធ្វើឲ្យមានព្យសនកម្មដល់ជនជាប់ចោទឡើយ ដូចជា ដោយធ្វើការប្រៀបធៀបជាដើម[53]។

21. ពាក់ព័ន្ធទៅនឹងគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* យើងយល់ឃើញថា ស្របតាមការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើគោលការណ៍នេះ គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទនេះ មានតួនាទីបន្ទាប់បន្សំប៉ុណ្ណោះនៅក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់ ហើយការអនុវត្តរបស់គោលការណ៍នេះត្រូវកម្រិតត្រឹមតែវិមតិសង្ស័យដែលនៅមាន បន្ទាប់ពីការអនុវត្តវិធានជាបទដ្ឋាននៃការបកស្រាយ[54]។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តី *Al Bashir* បានបញ្ជាក់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិ *"បានទទួលយកទាំងស្រុងនូវគោលការណ៍ទូទៅនៃការបកស្រាយលើគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទនេះ"*[55] ។ ក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Katanga* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់ពីកាលៈទេសៈដែលគោលការណ៍នេះអាចអនុវត្តបាន ដោយបញ្ជាក់ថា អនុលោមតាមអង្គជំនុំជម្រះតុលាការកំពូល គោលការណ៍នេះអាចអនុវត្តនៅក្នុងករណីដែល

---

[52] *សូមមើលជាឧទាហរណ៍* តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *S.W. តទល់នឹង ចក្រភពអង់គ្លេស*, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៤, ៦។ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY"), *រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត*, សំណុំរឿង លេខ IT-95-16-T, *សាលក្រម*, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០, កថាខណ្ឌ ៥៤៧។ *រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកដទៃទៀត*, សំណុំរឿង លេខ IT-05-87-T, *សាលក្រម*, 26 ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩, កថាខណ្ឌ ១៤៧។ តុលាការព្រហ្មទណ្ឌអន្តរជាតិ, *រដ្ឋអាជ្ញា តទល់នឹង Ntaganda*, សំណុំរឿង លេខ ICC-01/04-02/06, *សេចក្តីសម្រេចលើទីពីរ ស្តីពីការជំទាស់របស់មេធាវីការពារក្តី ចំពោះយុត្តាធិការរបស់តុលាការ ទាក់ទងបទចោទ ៦ និងបទចោទ៩*, ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧, កថាខណ្ឌ ៤៨។

[53] តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, *S.W. តទល់នឹង ចក្រភពអង់គ្លេស*, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៥។

[54] *សូមមើល* សំណុំរឿង ០០២-ឯកសារE50/3/1/4, *សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ ខៀវ សំផន លើសំណើសុំដោះលែង,* ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៣១។

[55] តុលាការព្រហ្មទណ្ឌអន្តរជាតិ, *រដ្ឋអាជ្ញា តទល់នឹង Al Bashir*, សំណុំរឿង លេខ ICC-02/05-01/09, *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដីកាឃុំខ្លួន Omar Hassan Ahmad Al Bashir*, ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ ១៥៦។

មានភាពមិនច្បាស់លាស់ ដែលនៅមានបន្ទាប់ពីបានបកស្រាយច្បាប់ តាមរយៈមធ្យោបាយទូទៅក្នុងការបកស្រាយ ដូចមានចែងនៅក្នុងមាត្រា ៣១ និង៣២ នៃអនុសញ្ញាទីក្រុងវីយ៉េន ស្តីពីច្បាប់សន្ធិសញ្ញា[56]។

22. ជាចុងក្រោយ នៅក្នុងការបកស្រាយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសច្បាប់ដែលមានលក្ខណៈជាច្បាប់ទំនៀមទម្លាប់ សេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចផ្តល់ជាជំនួយបានយ៉ាងច្រើន។ សេចក្តីសម្រេចទាំងនោះក៏មានភាពពាក់ព័ន្ធផងដែរចំពោះការវាយតម្លៃទៅលើលក្ខខណ្ឌតម្រូវនៃការប្រមើលមើលដឹងថាជាបទល្មើស។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចទាំងនោះមិនចងកាតព្វកិច្ចចំពោះ អ.វ.ត.ក ឡើយ[57]។

## គ. គោលបំណងនៃច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

23. មុនពេលតាក់តែងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធានអន្តរជាតិ ឆ្នាំ១៩៤៥ ("ធម្មនុញ្ញ Nuremberg") ការកំណត់ក្នុងន័យចង្អៀតអំពីឧក្រិដ្ឋកម្មសង្គ្រាម មានន័យថា ជនរងគ្រោះ ដែលជាជនជាតិនៃរដ្ឋដែលប្រព្រឹត្តបទល្មើស នឹងមិនត្រូវបានការពារពីអំពើសកម្ម ឬអកម្មដែលបង្កើតបានជាឧក្រិដ្ឋកម្មសង្គ្រាមឡើយ ប្រសិនបើអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងប្រឆាំងប្រទេសជាតិជាសត្រូវ[58]។ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិព្យាយាមដោះស្រាយចន្លោះប្រហោងនេះ នៅពេលពន្យល់អំពីសញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងឯកសាររបស់ខ្លួនពីឆ្នាំ ១៩៤៤ ដល់ឆ្នាំ១៩៤៥ ដែលបានបង្កើតជាការនាំមុខនៃមាត្រា ៦(គ) នៃធម្មនុញ្ញ Nuremberg

[56] តុលាការព្រហ្មទណ្ឌអន្តរជាតិ, *Le Procureur តទល់នឹង Katanga*, សំណុំរឿង លេខ ICC-01/04-01/07, *Jugement rendu en application de l'article 74 du Statut*, ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤, កថាខណ្ឌ ៥៣។

[57] *សូមមើល* សាលដីកាសំណុំរឿង ខុច, កថាខណ្ឌ ៩៧។ *សូមមើលផងដែរ* តុលាការ ICTY, *រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត*, សំណុំរឿង លេខ IT-95-16-T, *សាលក្រម*, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០, កថាខណ្ឌ ៥៤០ ដល់៥៤១។

[58] គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម របស់អង្គការសហប្រជាជាតិ, ឆ្នាំ ១៩៤៨, *ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម របស់អង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍ច្បាប់សង្គ្រាម*, ឆ្នាំ ១៩៤៨, His Majesty's Stationary Office, London, ទំព័រ ១៧៤។

។ គណៈកម្មការនេះបានអនុវត្តវិធីសាស្ត្រដែលថា ត្រូវផ្តល់អាទិភាពទៅលើលក្ខខណ្ឌច្បាប់ជាងទម្លាប់ករណីច្បាប់ដែលមានលក្ខណៈចង្អៀត ហើយយល់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខុសពីឧក្រិដ្ឋកម្មសង្គ្រាម គឺជា *"ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងបុគ្គលណាម្នាក់ ដោយមិនគិតអំពីជាតិសាសន៍ បុគ្គលដែលគ្មានប្រទេសត្រូវបានរួមបញ្ចូល ដោយសារតែពូជសាសន៍ ជាតិ ជំនឿសាសនា ឬជំនឿនយោបាយ ដោយមិនគិតថាតើអំពើនោះត្រូវបានប្រព្រឹត្តនៅទីណានោះទេ"*[59]។

24. ការបង្ហាញអំពីគោលដៅ និងគោលបំណងរបស់ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចរកឃើញនៅក្នុងយុត្តិសាស្ត្រនៃរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរ ដែលត្រូវបានជំនុំជម្រះតាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០។ នៅក្នុងរឿងក្តី *Einsatzgruppen* តុលាការបានកត់សម្គាល់ថា ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *"បានប្រមើលមើលដល់ការការពារមនុស្សជាតិនៅគ្រប់ពេលវេលា"*[60]។ នៅក្នុងរឿងក្តី *Alstötter* តុលាការបានបញ្ជាក់ថា ចេតនានៅពីក្រោយការណែនាំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺថា អនុលោមតាមច្បាប់អាល្លឺម៉ង់ មិនទទួលបានការការពារអ្វីឡើយ ដូច្នេះ អំពើដែលប្រព្រឹត្តដោយជនជាតិអាល្លឺម៉ង់ប្រឆាំងជនជាតិអាល្លឺម៉ង់ អាចត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមយុត្តាធិការរបស់ខ្លួន[61]។ នៅក្នុងរឿងក្តី *H* ផ្នែកព្រហ្មទណ្ឌរបស់តុលាការកំពូលប្រទេសអាល្លឺម៉ង់នៃតំបន់ដែលត្រួតត្រាដោយអង់គ្លេស បានបញ្ជាក់ថា ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ គឺ "យោងទៅតាមន័យ និងគោលបំណងរបស់ច្បាប់នេះ" ដែលសំដៅទៅលើការគាបសង្កត់ដែលមានផែនការ និងការចោទប្រកាន់ដែលធ្វើតាមអំពើចិត្ត និងដោយហិង្សា របស់រដ្ឋសង្គមនិយមប្រឆាំងនឹង "នរណាម្នាក់ដែលពួកគេមិនចូលចិត្ត ដោយមូលហេតុអ្វីក៏ដោយ" ជាពិសេសប្រសិនបើអ្នកទាំងនោះមិនធ្វើតាមគោលដៅរបស់ពួកគេដោយងងឹតងងល់ ក្នុងនាមជា

---

[59] *ដូចជើងទំព័រខាងលើ*, ទំព័រ ១៧៤, ១៧៦។

[60] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuernberg តាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០, Nuernberg, ខែតុលា ឆ្នាំ១៩៤៦ ដល់ ខែមេសា ឆ្នាំ១៩៤៩, Vol. IV, *សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកដទៃទៀត*, ទំព័រ ៤៩៧។

[61] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuernberg តាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០, Nuernbergខែតុលា ឆ្នាំ១៩៤៦ ដល់ ខែមេសា ឆ្នាំ១៩៤៩, Vol. III, *សហរដ្ឋអាមេរិក តទល់នឹង Josef Alstötter, និងអ្នកដទៃទៀត*, ទំព័រ ៩៧៣។

ឧបករណ៍អនុវត្តតាមនោះ[62]។ តុលាការបានបញ្ជាក់បន្ថែមថា នៅពេលដែលប្រព័ន្ធនេះបានក្លាយទៅជាគោលនយោបាយរដ្ឋ ប្រព័ន្ធបែបនេះរំលោភបំពានទៅលើមនុស្សជាតិ[63]។

25. មតិយោបល់ផ្នែកសិក្សាស្រាវជ្រាវបានចាត់ទុកការពន្យល់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយគណៈកម្មការ និងការតាក់តែងច្បាប់នៅក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញ Nuremberg ថាជា ការវិវត្តន៍សំខាន់នៅក្នុងច្បាប់ដែលព្យាយាមដោះស្រាយចំពោះអំពើសាហាវយង់ឃ្នងប្រឆាំងប្រជាជនស៊ីវិល ដែលមិនស្ថិតក្នុងនិយមន័យបច្ចេកទេសនៃឧក្រិដ្ឋកម្មដែលមានស្រាប់ ប៉ុន្តែ បានប្រឆាំងនឹងការតម្រូវនៃមនសិការសាធារណជន និងគោលការណ៍ជាទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ[64]។ ការបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងធម្មនុញ្ញ Nuremberg ក៏ត្រូវបានទទួលស្គាល់ផងដែរថាជាការកែប្រែផ្នែកច្បាប់មួយក្នុងការដាក់កំណត់ទៅលើបូរណភាពរបស់រដ្ឋ ដោយធានាថា ប្រជាជននៃរដ្ឋនោះត្រូវស្ថិតក្រោមការការពារដោយច្បាប់អន្តរជាតិ បើទោះបីជាពួកគេគឺជាកម្មវត្ថុនៃការវាយប្រហារដោយជនរួមជាតិរបស់ពួកគេក៏ដោយ[65]។

26. ហេតុដូច្នេះ គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់អន្តរជាតិ អាចត្រូវបានកំណត់ថាជា ការការពារប្រឆាំងការរំលោភសិទ្ធិមនុស្ស ដែលធ្វើឡើងជាទ្រង់ទ្រាយធំប្រឆាំង

---

[62] *សំណុំរឿង H*, ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៤៩, Entscheidungen in Strafsachen des Obersten Gerichtshofes für die Britische Zone, vol. II (W de Gruyter, Berlin, 1949), ទំព័រ ២៣៤, n. 26 ("*សំណុំរឿង H*") (ការបកប្រែរបស់ ក.ស.ច.ស)។

[63] *ដូចជើងទំព័រខាងលើ*

[64] E Schwelb, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", *British Yearbook of International Law*, Vol. 23, ឆ្នាំ ១៩៤៦, ទំព័រ ១៨៤ ដល់១៨៥។ M. Cherif Bassiouni, *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការវិវត្តន៍ជាប្រវត្តិសាស្ត្រ និងការអនុវត្តតាមកាលសម័យ*, ឆ្នាំ ២០១១, Cambridge University Press, New York, ទំព័រ ៩, ២៩, ៤៧៥។ Darryl Robinson, "ការកំណត់និយមន័យ 'ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅសន្និសិទទីក្រុងរ៉ូម", *The American Journal of International Law*, Vol. 93(1), ឆ្នាំ ១៩៩៩, ទំព័រ ៤៤។ Payam Akhavan, "ការសម្របសម្រួល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយច្បាប់សង្គ្រាម", *Journal of International Criminal Justice*, Vol. 6(1), ឆ្នាំ ២០០៨, ទំព័រ ២២ ដល់២៣។

[65] Beth Van Schaack, "និយមន័យនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការដោះស្រាយភាពមិនស្របគ្នា", *Columbia Journal of Transnational Law*, Vol. 37, ឆ្នាំ ១៩៩៩, ទំព័រ ៧៨០ ដល់៧៩១។

បុគ្គល រួមទាំងជនជាតិខ្លួនឯងផ្ទាល់របស់រដ្ឋនោះផង ដែលបើគ្មានច្បាប់អន្តរជាតិនេះទេ ពួកគេ មិនត្រូវបានការពារដោយច្បាប់ ឬទំនៀមទម្លាប់សង្គ្រាមដែលមានស្រាប់នោះទេ។

## ឃ. ការបកស្រាយលើពាក្យ *ប្រជាជនស៊ីវិល* នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### *៥. ការពិចារណាបឋម*

27. រឿងក្តីព្រហ្មទណ្ឌអន្តរជាតិដែលត្រូវបានជំនុំជម្រះនៅមុនឆ្នាំ ១៩៧៥ មិនបានបកស្រាយលម្អិត អំពីអត្ថន័យនៃពាក្យ *ប្រជាជនស៊ីវិល* សម្រាប់គោលបំណងនៃធាតុផ្សំទូទៅរបស់ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិឡើយ។ ទោះបីជារឿងក្តីខ្លះបានផ្តល់នូវគោលការណ៍ណែនាំដែលពាក់ព័ន្ធ សម្រាប់ដំណោះស្រាយលើបញ្ហានេះក៏ដោយ តែការពិភាក្សាលម្អិតផ្នែកតុលាការទៅលើអត្ថ ន័យនៃពាក្យនេះ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទើបតែចាប់ផ្តើមឡើងនៅក្នុង ទសវត្សរ៍ឆ្នាំ ១៩៩០ ប៉ុណ្ណោះ គឺនៅពេលដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") បានទទួលយុត្តាធិការក្នុងការជំនុំជម្រះលើឧក្រិដ្ឋ កម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងបរិបទនៃជម្លោះ ជនជាតិយូហ្គោស្លាវីប៉ុណ្ណោះ។

28. ទោះបីជាតុលាការ ICTY, តុលាការមិនអចិន្ត្រៃយ៍ដទៃទៀត, អ.វ.ត.ក និងតុលាការព្រហ្ម ទណ្ឌអន្តរជាតិ សុទ្ធតែបានពិភាក្សាអំពីអត្ថន័យនៃពាក្យ *ប្រជាជនស៊ីវិល* ក៏ដោយ ប៉ុន្តែមិនមាន រឿងក្តីណាមួយបានបកស្រាយពាក្យនេះនៅក្នុងបរិបទនៃសេណារីយ៉ូដែលត្រូវបានប្រមើល មើលជាមុននៅក្នុងបញ្ហានេះឡើយ។ ការពិភាក្សាបានផ្តោតតែទៅលើអត្ថន័យនៃពាក្យ *ប្រជា ជនស៊ីវិល* ដែលយោងទៅប្រជាជននៃភាគីប្រឆាំងម្ខាងទៀតនៅក្នុងជម្លោះប្រដាប់អាវុធជាតិ ឬអន្តរជាតិ។

29. ដើម្បីដោះស្រាយបញ្ហានេះ យើងនឹងពិនិត្យមើលជាដំបូងទៅលើភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និងទស្សនៈច្បាប់ នៅមុនឆ្នាំ១៩៧៥ ដើម្បីសម្រេចថាតើ នៅក្នុងឆ្នាំ១៩៧៥ *ប្រជាជនស៊ីវិល* ត្រូវបានរាប់បញ្ចូល និងអាចត្រូវបានគេយល់ថារួមបញ្ចូល ទាំងកងកម្លាំងប្រដាប់អាវុធផ្ទាល់ របស់រដ្ឋ ឬអង្គការនោះដែរឬទេ។ បន្ទាប់មក យើងនឹងវិភាគលើការពន្យល់ពាក្យនេះដោយ តុលាការផ្សេងៗដែលបានបកស្រាយទៅលើពាក្យនេះ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០មក។

ការពិនិត្យនេះនឹងបង្ហាញថា ទោះបីជាក្នុងពេលបច្ចុប្បន្ន ភាគច្រើននៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការកូនកាត់ បានកំណត់និយមន័យពាក្យ *ប្រជាជនស៊ីវិល* ក្នុងលក្ខណៈចង្អៀត និងផ្អែកទៅលើអត្ថន័យនៃពាក្យនេះនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិក៏ដោយ តែយុត្តិសាស្ត្រនេះបានកើតចេញពីបរិបទនៃរឿងក្តីដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវមានទំនាក់ទំនងមិនអាចកាត់ផ្តាច់បានពីជម្លោះប្រដាប់អាវុធដែលកំពុងបន្ត។ បញ្ហាចម្បងដែលត្រូវដោះស្រាយក្នុងការឆ្លើយតបចំពោះបញ្ហាចំពោះមុខនេះគឺថាតើការបកស្រាយបែបនេះ សមស្រប និងអាចអនុវត្តបានដែរឬទេ នៅក្នុងពេលសន្តិភាព ឬចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលគ្រាន់តែត្រូវបានប្រព្រឹត្តឡើង នៅក្នុងពេលជម្លោះប្រដាប់អាវុធកំពុងបន្ត តែមិនមានជាប់ទាក់ទងក្នុងបរិបទនៃជម្លោះនោះ ឬក៏ថា ការបកស្រាយនេះត្រូវតែអនុវត្តតាមចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ។

### *៦. ការពិនិត្យមើលលើការអនុវត្តរបស់រដ្ឋ និងទស្សនៈច្បាប់មុនឆ្នាំ១៩៧៥*

### *និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមុនឆ្នាំ ១៩៧៥*

30. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបាន "តាក់តែងឡើង" ជាលើកដំបូង[66] នៅក្នុងខែសីហា ឆ្នាំ ១៩៤៥ នៅក្នុងធម្មនុញ្ញ Nuremberg។ នៅក្នុងខែធ្នូ ឆ្នាំ១៩៤៥ មហាអំណាចសម្ព័ន្ធមិត្តបានចេញច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០[67] ដែលជាសំខាន់បានបង្កើតឡើងជាថ្មី អំពីនិយមន័យនៃធម្មនុញ្ញ Nuremberg លើកលែងតែលក្ខខណ្ឌតម្រូវដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវប្រព្រឹត្តឡើងដោយមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ("ចំណងទាក់ទង")[68]។ ធម្មនុញ្ញ Nuremberg ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ និងនិយមន័យទាំងអស់

---

[66] ពាក្យដែលប្រើប្រាស់នៅទីនេះ គឺស្ថិតក្នុងន័យមិនច្បាស់លាស់ គឺមិនមែនជាពាក្យពិតប្រាកដ សម្រាប់ការអនុម័តច្បាប់ដែលមិនធ្លាប់ត្រូវបានធ្វើឡើង មុនពេលមានលក្ខន្តិកៈទីក្រុងរ៉ូមឡើយ។

[67] ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ការដាក់ទណ្ឌកម្មចំពោះបុគ្គល ដែលមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥។

[68] *សូមមើល* សំណុំរឿង លេខ 003-D87/2/1.7/1, *សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយជម្លោះប្រដាប់អាវុធ,* ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ២៤ ដល់ ២៧, ៣៣ ("សេចក្តីសម្រេចស្តីពីចំណងទាក់ទង")។ សំណុំរឿង ០០២ ឯកសារ F36, *សាលដីកា,* ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦, កថាខណ្ឌ ៧១៤ ("សាលដីកាសំណុំរឿង ០០២/០១")។

របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើកលែងតែនិយមន័យមួយរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានពន្យល់ និង/ឬ អនុម័តិនៅមុនឆ្នាំ១៩៧៥ កំណត់ថា ដើម្បីឱ្យអំពើជាក់លាក់មួយអាចក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើនោះចាំបាច់ត្រូវប្រព្រឹត្តឡើងនៅក្នុងបរិបទនៃការវាយប្រហារជាទ្រង់ទ្រាយធំ ឬជាប្រព័ន្ធ "ប្រឆាំងប្រជាជនស៊ីវិល"[69]។ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏បានចែងពីលក្ខខណ្ឌតម្រូវដូចគ្នានេះដែរ[70]។

31. ដោយយល់ឃើញថា ចំណងទាក់ទងលែងជាធាតុផ្សំសំខាន់ទៀតហើយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មកត្រឹមឆ្នាំ ១៩៧៥ នោះ[71] ហើយ លើកលែងតែគោលការណ៍ Nuremberg[72] មិនមាននិយមន័យជាផ្លូវការនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងឡើយ មុនពេលនិយមន័យនេះត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់តុលាការមិនអចិន្ត្រៃយ៍ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ នោះ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងមាត្រា ២(១) នៃច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ នឹងត្រូវបានប្រើប្រាស់ជាចំណុចយោងនៅក្នុងការពិនិត្យមើលទៅលើយុត្តិសាស្ត្រពាក់ព័ន្ធទៅនឹងការសម្រេចទៅលើបញ្ហាចំពោះមុខនេះ។ មាត្រា២(១)(គ) កំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានចែងដូចតទៅនេះ៖

---

[69] *សូមមើល* ធម្មនុញ្ញរបស់តុលាការយោធានអន្តរជាតិ- ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងលើការជំនុំជម្រះ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៃ Axis អឺរ៉ុប ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ មាត្រា ៦(គ) (“ធម្មនុញ្ញ Nuremberg”)។ ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ការដាក់ទណ្ឌកម្មចំពោះបុគ្គល ដែលមានពិរុទ្ធភាពលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥, មាត្រា ២(១)(គ)។ គោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញ នៃតុលាការ Nuremberg និងនៅក្នុងសាលក្រមតុលាការ, *Yearbook of the International Law Commission* (1950), Vol. II, គោលការណ៍ VI, ទំព័រ ៣៧៧។

[70] សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧០៧។

[71] *សូមមើល* សេចក្តីសម្រេចស្តីពីចំណងទាក់ទង, កថាខណ្ឌ ៨០។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧២១។

[72] និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានតាក់តែងឡើងក្នុងឆ្នាំ ១៩៥០ តាមគោលការណ៍ VI នៃគោលការណ៍ Nuremberg ដែលនៅមានរួមបញ្ចូលលក្ខខណ្ឌតម្រូវចំណងទាក់ទង។ ទោះជាយ៉ាងនេះក្តីដោយសារតែចំណងទាក់ទង ត្រូវបានបំបែកចេញត្រឹមឆ្នាំ ១៩៧៥ វាហាក់ដូចជាការប្រសើរជាង ក្នុងការពឹងផ្អែកទៅលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុង មាត្រា ២(១)(គ) នៃច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដែលជានិយមន័យវិជ្ជមានរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនៅជាធរមានក្នុងឆ្នាំ ១៩៧៥។ *សូមមើល* សេចក្តីសម្រេចស្តីពីចំណងទាក់ទង, កថាខណ្ឌ ៤៧។

អំពើសាហាវយង់ឃ្នង់ និងបទល្មើស ដែលរួមបញ្ចូល តែលើសពី អំពើមនុស្សឃាត ការសម្លាប់រង្គាល់ ការដាក់ឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងពន្ធនាគារ ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ឬអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានប្រព្រឹត្ត ចំពោះ **ប្រជាជនស៊ីវិល** ឬការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ ឬជំនឿសាសនា ទោះបីជាបានរំលោភបំពាន ឬមិនបានរំលោភបំពានទៅលើច្បាប់ជាតិរបស់ប្រទេសដែលត្រូវបានប្រព្រឹត្តនោះក៏ដោយ[73]។ (ដោយគូសបញ្ជាក់បន្ថែម)

32. យើងកត់សម្គាល់ថា លិខិតុបករណ៍មួយ នៅក្នុងឆ្នាំ១៩៤៦ បានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមិនមានលក្ខខណ្ឌតម្រូវថា អំពើនោះត្រូវប្រព្រឹត្តឡើងនៅក្នុងបរិបទនៃការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះទេ។ ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ដែលត្រូវបានចេញកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ ១៩៤៦ នៅពេលដំបូងបានបញ្ចូលលក្ខខណ្ឌតម្រូវប្រជាជនស៊ីវិលនេះ នៅក្នុងមាត្រា៥របស់ធម្មនុញ្ញ ដែលបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[74]។ តាមដីការួមលេខ ២០ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ១៩៤៦ មេបញ្ជាការកំពូលនៃមហាអំណាចសម្ព័ន្ធមិត្តបានដកចេញលក្ខខណ្ឌតម្រូវប្រជាជនស៊ីវិលនេះចេញពីមាត្រា៥[75]។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរនេះហាក់ដូចជាត្រូវបានធ្វើឡើងតាមការបង្គាប់របស់រដ្ឋអាជ្ញា ត្រឹមពីរបីថ្ងៃមុនពេលចាប់ផ្តើមការជំនុំជម្រះ ដែលនេះជាកាលៈទេសៈមួយដែលត្រូវទទួលរងការរិះគន់ពីសំណាក់អ្នកសិក្សាសម័យនោះ និងចៅក្រមមួយរូបនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា[76]។ លើសពីនេះទៀត ការចេញជាឯក

---

[73] ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០, ការដាក់ទណ្ឌកម្មលើបុគ្គលដែលមានពិរុទ្ធភាព ពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥, មាត្រា ២(១)(គ), អាចរកបាននៅ http://avalon.law.yale.edu/imt/imt10.asp.

[74] ដីកាទូទៅលេខ ១ អាចរកបាននៅ http://imtfe.law.virginia.edu/collections/tavenner/1/3/general-order-number-1-charter-international-military-tribunal-far-east.

[75] ដីកាទូទៅលេខ ២០ អាចរកបាននៅ http://imtfe.law.virginia.edu/collections/tavenner/2/1/general-order-no-20-charter-international-military-tribunal-far-east.

[76] *សូមមើល* Neil Boister & Robert Cryer, *The Tokyo តុលាការយោធាអន្តរជាតិទីក្រុងតូក្យូ៖ ការវាយតម្លៃឡើងវិញ,* Oxford, Oxford University Press, ឆ្នាំ ២០០៨, ទំព័រ ១៥៦ ដល់១៥៧។ Neil Boister & Robert Cryer, ឯកសារ

គោរភាគីនូវធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ាដោយនាយឧត្តមសេនីយ៍ MacArthur ធ្វើឲ្យតម្លៃនៃធម្មនុញ្ញនេះ សម្រាប់ការវាយតម្លៃទៅលើលក្ខណៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាន់តែមានកម្រិតទៀត[77]។ ហេតុដូច្នេះ យើងមិនចាត់ទុកថាជាការត្រឹមត្រូវក្នុងការផ្តល់តម្លៃណាមួយចំពោះធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ សម្រាប់ចុងបូព៌ា ដែលត្រូវបានកែសម្រួល នៅក្នុងការសម្រេចទៅលើបញ្ហាចំពោះមុខនេះទេ។

*ទឡ្ហីករណ៍អំពីការធ្វើទុក្ខបុកម្នេញដែលជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

33. ជាការកត់សម្គាល់បឋម ពាក្យពេចន៍នៃមាត្រា ២(១) នៃច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ អនុញ្ញាតឲ្យមានការបកស្រាយថា ធាតុផ្សំទូទៅនៃការវាយប្រហារចំពោះប្រជាជនស៊ីវិល មិនអនុវត្តចំពោះការធ្វើទុក្ខបុកម្នេញដែលជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ប្រសិនបើការបកស្រាយនេះត្រូវបានទទួលយក ដំណោះស្រាយលើបញ្ហាចំពោះមុខ នឹងមិនមានភាពពាក់ព័ន្ធទៀតឡើយ ចំពោះការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ។ ទឡ្ហីករណ៍នេះត្រូវបានលើកឡើងបន្ថែមទៀតដោយអ្នកមិនមែនជាគូភាគីនៃរឿងក្តី ហើយជាត្រូវបានប្រើប្រាស់ ឧទាហរណ៍ដោយ Antonio Cassese តាំងពីយូរមកហើយ[78]។

34. យ៉ាងណាក៏ដោយ មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កំណត់ច្បាស់លាស់ថា ការធ្វើទុក្ខបុកម្នេញដែលជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវប្រព្រឹត្តឡើងក្នុងបរិបទនៃការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល។ ហេតុដូច្នេះ ក្នុងការអនុវត្តបើទោះបីជាទឡ្ហីករណ៍អំពីការធ្វើទុក្ខបុកម្នេញត្រូវបានទទួលយកក៏ដោយ តែ អ.វ.ត.ក មានយុត្តាធិការតែត្រឹមលើការធ្វើទុក្ខបុកម្នេញទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃការវាយប្រហារជាទ្រង់ទ្រាយធំ ឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលប៉ុណ្ណោះ។ តាមរយៈឧទាហរណ៍ បើទោះបីជាតុលាការ ICTY បានសម្រេចក្នុងឆ្នាំ ១៩៩៥ ថា មានការកំណត់

---

របស់តុលការយោធាអន្តរជាតិទីក្រុងតូក្យូ៖ ធម្មនុញ្ញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសាលក្រម, Oxford, Oxford University Press, ឆ្នាំ ២០០៨, ទំព័រ ១៣២៤, កថាខណ្ឌ ១០៣១។

[77] *សូមមើល* សេចក្តីសម្រេចស្តីពីចំណងទាក់ទង, កថាខណ្ឌ ២៨។

[78] Antonio Cassese និងអ្នកដទៃទៀត, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese*,Third Edition, ឆ្នាំ ២០១៣, Oxford University Press, Oxford, ទំព័រ ១០២។

យ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលែងតម្រូវឱ្យមានការបង្ហាញពីចំណងទាក់ទងក៏ដោយ តែតុលាការ ICTY បានទទួលស្គាល់ថា ការដាក់បញ្ចូលលក្ខខណ្ឌតម្រូវនេះទៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY បង្កើតបានជាការកម្រិតកំណត់ផ្នែកយុត្តាធិការមួយ[79]។ ហេតុដូច្នេះ ទឡ្ហីករណ៍អំពីការធ្វើទុក្ខបុកម្នេញនឹងមិនត្រូវបានពិភាក្សាបន្ថែមទៀតឡើយនៅក្នុងសេចក្តីសម្រេចនេះ។

*ប្រជាជនស៊ីវិលនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ*

35. មុនពេលមានការបង្កើតតុលាការមិនអចិន្ត្រៃយ៍ និងការត្រួតពិនិត្យដោយម៉ត់ចត់ទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ តាមយុត្តាធិការរបស់តុលាការមិនអចិន្ត្រៃយ៍ទាំងនោះ ប្រភពដែលអាចជួយដល់ការបកស្រាយលើពាក្យប្រជាជនស៊ីវិលនៅក្នុងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ មានតិច និងខុសឆ្ងាយណាស់។

36. សាលក្រមព្រហ្មទណ្ឌអន្តរជាតិដំបូងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺសាលក្រមរបស់តុលាការយោធាអន្តរជាតិ ("សាលក្រមតុលាការ Nuremberg")[80]។ ការវិភាគទៅលើសំអាងហេតុបង្ហាញថា ទោះបីជាចៅក្រមមិនបានវិភាគឱ្យស៊ីជម្រៅទៅលើអត្ថន័យនៃពាក្យ *ប្រជាជនស៊ីវិល* ក៏ដោយ តែចៅក្រមបានបញ្ជាក់ម្តងហើយម្តងទៀតពី ភាព "ស៊ីសង្វាក់" "ជាប្រព័ន្ធ" និង "រៀបចំផែនការ" នៃប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញដោយអមនុស្សធម៌ និងឧក្រិដ្ឋកម្មផ្សេងទៀត ដែលត្រូវបានប្រព្រឹត្ត "ជាទ្រង់ទ្រាយធំ" ដោយរបបណាហ្ស៊ី ដោយមិនបានធ្វើការស៊ើបអង្កេត ដែលជារឿងធម្មតានៅក្នុងសាលក្រមព្រហ្មទណ្ឌអន្តរជាតិស្តីពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានចេញដោយតុលាការអន្តរជាតិ និងតុលាការកូនកាត់ ដែលបានបង្កើត

---

[79] *សូមមើល* តុលាការ ICTY, *រដ្ឋអាជ្ញា តទល់នឹង Tadić*, សំណុំរឿង លេខ IT-94-1-AR72, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ស្តីពីយុត្តាធិការ, ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥, កថាខណ្ឌ ១៣៨ ដល់ ១៤២។

[80] តុលាការយោធាអន្តរជាតិ, *សាលក្រម*, ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦, បោះពុម្ពឡើងវិញនៅក្នុងការជំនុំជម្រះ ឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ, Vol. I, ("សាលក្រម Nuremberg ")។

ឡើងក្រោយទសវត្សរ៍ឆ្នាំ ១៩៩០ ទាក់ទងធាតុផ្សំនៃប្រជាជន និងស្ថានភាពនៃប្រជាជនគោលដៅ[81]។

37. រឿងក្ដីដែលត្រូវបានជំនុំជម្រះក្រោមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ មិនបានផ្ដល់ការវិភាគច្បាស់លាស់ឡើយអំពីលក្ខខណ្ឌតម្រូវ *ប្រជាជនស៊ីវិល*។ តាមពិតទៅ ប្រហែលគ្នានឹងសាលក្រម Nuremberg ដែរ មិនមានការព្យាយាមខ្លាំងណាមួយក្នុងការបញ្ជាក់ពីឋានៈផ្លូវការនៃក្រុមប្រជាជនគោលដៅឡើយ។ ទោះជាយ៉ាងនេះក្ដី ការពិចារណាមួយចំនួនរបស់តុលាការដែលបានជំនុំជម្រះរឿងក្ដីទាំងអស់នេះ បានបង្ហាញពីការយល់ឃើញរបស់ពួកគេ ទៅលើកម្រិតនៃការការពារដែលផ្ដល់ដោយច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអនុលោមទៅតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានកំណត់និយមន័យនៅខាងលើ។

38. តុលាការជាច្រើន នៅពេលកាត់សេចក្ដីលើការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានពិនិត្យមើលជាសំខាន់ទៅលើ ទ្រង់ទ្រាយធំ និងលក្ខណៈជាប្រព័ន្ធ នៃការវាយប្រហារ ជាជាងពិនិត្យទៅលើឋានៈផ្លូវការនៃជនរងគ្រោះដោយការវាយប្រហារ។ ឧទាហរណ៍ នៅក្នុងរឿងក្ដី *Altstötter* តុលាការបានបញ្ជាក់ថា ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ចែងពីការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តចំពោះប្រជាជនអាល្លឺម៉ង់ ដោយមិនបានបញ្ជាក់លម្អិតបន្ថែមអំពីឋានៈរបស់ប្រជាជនទាំងនោះ ក្នុងករណីដែលមានភស្តុតាងនៃ "ការចូលរួមដោយចេតនានៅក្នុងនីតិវិធីដែលបានអនុម័ត ឬដែលរៀបចំដោយរដ្ឋាភិបាលជាប្រព័ន្ធដែលបង្កើតបានជាអំពីសាហាវយង់ឃ្នង និងបទល្មើសនៃប្រភេទដែលមានចែងច្បាស់លាស់ក្នុងច្បាប់ និងប្រព្រឹត្តទៅលើប្រជាជន ឬបង្កើតបានជាការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូល

[81] សាលក្រម Nuremberg, ទំព័រ ២៤៧, ២៥០, ២៥៤។

ហេតុនយោបាយ ពូជសាសន៍ ឬជំនឿសាសនា"[82]។ វិធីសាស្ត្រប្រហែលគ្នានេះត្រូវបានយកមកប្រើនៅក្នុងរឿងក្តី *Ohlendorf* និងអ្នកដទៃទៀត[83]។

39. រឿងក្តីចំនួនបីដែលត្រូវបានសម្រេចដោយតុលាការកំពូលអាល្លឺម៉ង់នៃតំបន់ដែលគ្រប់គ្រងដោយអង់គ្លេស ត្រូវបានដកស្រង់យ៉ាងច្រើនដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកដែលមិនមែនជាគូភាគីនៃរឿងក្តី ដើម្បីគាំទ្រដល់ដំណោះស្រាយវិជ្ជមានសម្រាប់បញ្ហានៅចំពោះ មុខនេះ។ មេធាវីការពារក្តី មាស មុត អោ អាន និង យឹម ទិត្យ បានពិភាក្សាយ៉ាងច្រើនអំពីយុត្តិសាស្ត្រនេះ ដោយលើកទឡ្ហីករណ៍ថា បញ្ហានេះមិនពាក់ព័ន្ធជាមួយដំណោះស្រាយសម្រាប់បញ្ហានៅចំពោះមុខនេះឡើយ ប៉ុន្តែពាក់ព័ន្ធជាមួយបញ្ហាដែលមិនចម្រូងចម្រាស់ទៅវិញ គឺបញ្ហាដែលថា កងទ័ពអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[84]។ តាមពិតទៅរឿងក្តីទាំងនេះទាក់ទងជាមួយកងទ័ពដែលក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយរឿងក្តីនេះមិនបានពិភាក្សាលម្អិតអំពីលក្ខខណ្ឌតម្រូវប្រជាជនស៊ីវិលឡើយ យ៉ាងហោចណាស់មិនដល់កម្រិតដែលត្រូវបានពិភាក្សានៅក្នុងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មក។ ទោះជាយ៉ាងណាក្តី រឿងក្តីទាំងអស់នេះបានផ្តល់ការយល់ដឹងអំពីការយល់ឃើញរបស់តុលាការទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងការមិនបានផ្តោតសំខាន់ទៅលើឋានៈផ្លូវការ (កងទ័ព ឬជនស៊ីវិល) របស់ក្រុមគោលដៅនៃការរំលោភបំពានសិទ្ធិមនុស្ស នៅពេលអំពើនោះត្រូវបានប្រព្រឹត្តជាទ្រង់ទ្រាយធំ ឬជាប្រព័ន្ធនោះ។

---

[82] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuernberg តាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០, Nuernberg, ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩, Vol. III, *សហរដ្ឋអាមេរិក តទល់នឹង Josef Alstotter និងអ្នកដទៃទៀត*, ទំព័រ ៩៨២។

[83] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuernberg តាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០, Nuernberg, ខែតុលា ឆ្នាំ១៩៤៦ ដល់ខែមេសា ឆ្នាំ១៩៤៩, Vol. IV, *សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកដទៃទៀត*, ទំព័រ ៤៩៨។

[84] ចម្លើយតបរបស់ មាស មុត, កថាខណ្ឌ ២៦ ដល់២៧។ សារណារបស់ អោ អាន, កថាខណ្ឌ ៣៨។ សារណារបស់ យឹម ទិត្យ, កថាខណ្ឌ ២១ ដល់២៥, ២៨។

40. នៅក្នុងរឿងក្តី *P* និងអ្នកដទៃទៀត តុលាការបានបញ្ជាក់ថា "នរណាក៏ដោយ ដោយពិចារណាទៅលើភាពមិនលម្អិតនៃធាតុផ្សំបទល្មើសជាតំណាង ដូចមានរៀបរាប់នៅក្នុង (ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០) មិនអាចជឿថា អំពើ **ក្នុងចំណោមករណីដាច់ពីគ្នា** មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ" នៅពេលដែលអំពើទាំងនោះស្ថិតក្នុង "ប្រព័ន្ធនិងចំនួនច្រើនលើសលប់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តក្នុងការគ្រប់គ្រងរបស់ណាហ្ស៊ី" (បញ្ជាក់បន្ថែម)[85]។ ចំពោះធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តុលាការបានបញ្ជាក់ថា "ដើម្បីបំពេញបានតាមធាតុផ្សំខាងក្នុងរបស់ឧក្រិដ្ឋកម្មនេះ ជាការចាំបាច់បន្ថែមទៀតដែលថា បំណងដោយចេតនាក្នុងការបង្កព្យសនកម្ម រួមទាំងថា ព្យសនកម្មនោះជាប់ទាក់ទងជាមួយនឹងប្រព័ន្ធនៃការគ្រប់គ្រងដោយផ្តាច់ការ និងអំពើហិង្សា"[86]។

41. នៅក្នុងរឿងក្តី H តុលាការបានបញ្ជាក់ថា ដើម្បីបំពេញតាមធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាការចាំបាច់ដែលជនជាប់ចោទត្រូវដឹងអំពីទំនាក់ទំនងរវាងអំពើរបស់ខ្លួន "ជាមួយប្រព័ន្ធនៃអំពើហិង្សា និងការគ្រប់គ្រងផ្តាច់ការ"[87]។ ពាក់ព័ន្ធទៅនឹងបញ្ហាចំពោះមុខនេះ តុលាការក្នុងពេលកន្លងមកបានកំណត់រួចហើយពីនិយមន័យនៃប្រព័ន្ធ និងការគាប់សង្កត់ និងការធ្វើទុក្ខបុកម្នេញដែលបានប្រព្រឹត្តតាមអំពើចិត្ត និងដោយហិង្សា ដោយរដ្ឋសង្គមនិយមប្រឆាំងនឹង "**នរណាម្នាក់**ដែលពួកគេមិនចូលចិត្តដោយមូលហេតុអ្វីក៏ដោយ" (បញ្ជាក់បន្ថែម)[88] ដែលជាការលើកឡើងស្របជាមួយពាក្យពេចន៍របស់តុលាការក្នុងរឿងក្តី *Einsatzgruppen* ដែលបញ្ជាក់ថា ច្បាប់មនុស្សធម៌ "ប្រមើលមើលពីការការពារមនុស្សជាតិនៅគ្រប់ពេលវេលា"[89](បញ្ជាក់បន្ថែម)។

---

[85] រឿងក្តី *P និងអ្នកដទៃទៀត,* ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៨, Entscheidungen in Strafsachen des Obersten Gerichtshofes für die Britische Zone,vol. I (1949), ទំព័រ ២២៨, n. V (ការបកប្រែរបស់ ក.ស.ច.ស)។

[86] *ដូចជើងទំព័រខាងលើ*, ទំព័រ ២២៤, n. III (ការបកប្រែរបស់ ក.ស.ច.ស)។

[87] *សំណុំរឿង H*, ទំព័រ ២៤៦, n. 26 (ការបកប្រែរបស់ ក.ស.ច.ស)។

[88] *ដូចជើងទំព័រខាងលើ*, ទំព័រ ២៣៤, n. 26 (ការបកប្រែរបស់ ក.ស.ច.ស)។

[89] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuernberg តាមច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០, Nuernberg, ខែតុលា ឆ្នាំ១៩៤៦ ដល់ ខែមេសា ឆ្នាំ១៩៤៩, Vol. IV, *សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកដទៃទៀត*, ទំព័រ ៤៩៧។

42. ចុងក្រោយ នៅក្នុងរឿងក្ដី *R* តុលាការបានបញ្ជាក់ថា ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជា "ទំនាក់ទំនងដ៏ចាំបាច់រវាងបទល្មើស និងការគ្រប់គ្រងផ្ដាច់ការរបស់ពួកសង្គមនិយម ដែលជាកាលៈទេសៈបន្ថែមដែលធ្វើឱ្យបទល្មើសបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ជនរងគ្រោះ និងចុងក្រោយគឺ ឥទ្ធិពលនៃបទល្មើសទៅលើមនុស្សជារួម"[90]។

43. ជាការសន្និដ្ឋាន ទោះបីជាលក្ខខណ្ឌតម្រូវនៃពាក្យប្រជាជនស៊ីវិល គឺជាផ្នែកមួយនៃច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានអនុវត្តនៅក្រោយសង្គ្រាមលោកលើកទីពីរក៏ដោយ តែតុលាការជាច្រើនដែលអនុវត្តច្បាប់នេះ យល់ថា ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញ នៅពេលដែលឧក្រិដ្ឋកម្មនីមួយៗជាប់ទាក់ទងជាមួយនឹងប្រព័ន្ធនៃការរំលោភសិទ្ធិមនុស្សជាទ្រង់ទ្រាយធំដោយអាជ្ញាធរណាមួយ ដែលមិនមែនធ្វើឡើងនៅក្នុងពេលមានប្រតិបត្តិការប្រយុទ្ធផ្នែកយោធាទេ។ នៅពេលមានកាលៈទេសៈទាំងអស់នេះ តុលាការសម្រេចថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្ត ដោយមិនមានការស៊ើបអង្កេតបន្ថែមទៅលើឋានៈផ្លូវការរបស់មនុស្សដែលបានទទួលរងឥទ្ធិពលដោយប្រព័ន្ធនេះ។ ដូចដែលបានពិភាក្សានៅផ្នែកខាងក្រោម អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក៏បានផ្ដល់សំអាងហេតុថា ក្រៅពីឋានៈជាជនស៊ីវិលផ្លូវការ គឺស្ថានភាពជារួមនៃឧក្រិដ្ឋកម្មនោះ ដែលកំណត់លក្ខណៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ។ វិធីសាស្ត្រដែលយើងចាត់ទុកថាស្របគ្នាជាមួយគោលដៅ និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានផ្ដល់ភស្ដុតាងនៃការបកស្រាយក្នុងន័យទូលាយ ទៅលើពាក្យប្រជាជនស៊ីវិល នៅក្រោយសង្គ្រាមលោកលើកទីពីរ។

លិខិតុបករណ៍អន្តរជាតិមុនឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធ

44. មាត្រា II នៃអនុសញ្ញាស្ដីពីការរារាំង និងការដាក់ទណ្ឌកម្ម ទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ("អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍") ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ហើយដែលកម្ពុជាបានចូលជាសមាជិកនៅក្នុងឆ្នាំ ១៩៥០ នោះ មិនមានកម្រិតការហាមឃាត់ទៅលើប្រជាជនស៊ីវិលនោះឡើយ នៅ

---

[90] រឿងក្ដី *R* ,ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ១៩៤៨, Entscheidungen in Strafsachen des Obersten Gerichtshofes für die Britische Zone, vol. I (1949), ទំព័រ ៤៩ (ការបកប្រែរបស់ ក.ស.ច.ស)។

ក្នុងការកំណត់និយមន័យនៃអំពើប្រល័យពូជសាសន៍។ ប៉ុន្តែ អនុសញ្ញានេះបានហាមឃាត់ការរំលោភសិទ្ធិមនុស្សមួយចំនួន ដែលធ្វើឡើងដោយមានចេតនាប្រល័យពូជសាសន៍ ទៅលើមនុស្សទាំងអស់។ ប្រហែលគ្នានេះ មាត្រា II នៃអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មអាប៉ាថេត ("អនុសញ្ញាស្តីពីអាប៉ាថេត") បន្ទាប់ពីបានកំណត់នអាប៉ាថេតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហើយ បានធ្វើការហាមឃាត់ទៅលើវិធានការរើសអើង និងអំពើរំលោភបំពានលើសិទ្ធិមនុស្សមួយចំនួន ប្រឆាំងនឹងមនុស្សទាំងអស់។

45. អំពើប្រល័យពូជសាសន៍ និងអាប៉ាថេត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនតម្រូវឱ្យមានភស្តុតាងនៃធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឡើយ។ បន្ថែមពីលើនេះ ឧក្រិដ្ឋកម្មអាប៉ាថេត មានប្រភពដើមប្រវត្តិសាស្ត្រជាក់លាក់ណាស់។ ដោយសារតែលក្ខណៈពិសេសរបស់អាប៉ាថេត ការពិភាក្សានៅមុនពេលអនុម័តលើចំណុចនេះ គ្មានអ្វីចម្លែកទេ មិនផ្តោតទៅលើឋានៈរបស់អ្នកអាចជាជនរងគ្រោះ ថាជាកងទ័ព ឬជនស៊ីវិល។ ហេតុដូច្នេះ ភាពជាប់ពាក់ព័ន្ធផ្ទាល់នៃការពិភាក្សាទាំងនេះចំពោះការបកស្រាយទៅលើពាក្យប្រជាជនស៊ីវិល ដែលមានចែងក្នុងមាត្រា ៥ មានតិចតួចណាស់។ ទោះជាយ៉ាងនេះក្តី លិខិតុបករណ៍ទាំងអស់នេះឆ្លុះបញ្ចាំងពីសេចក្តីសម្រេចរបស់សហគមន៍អន្តរជាតិក្នុងការការពារទៅលើបុគ្គលទាំងអស់ពីការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តឡើងទាំងនៅពេលសន្តិភាព ឬនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ គឺនៅពេលដែលការប្រព្រឹត្តិនោះធ្វើឡើង មិនមែនដោយសារភាពចាំបាច់ផ្នែកយោធាទេ។ ហេតុដូច្នេះ យើងសន្និដ្ឋានថា ចំណុចទាំងអស់នេះមានភាពពាក់ព័ន្ធជាមួយនឹងបញ្ហាចំពោះមុខនេះ បើទោះបីជាត្រង់តែចំណុចនៃការអាចប្រមើលមើលដឹងពីគោលការណ៍និត្យានុកូលភាពក៏ ដោយ។

### *៧. ការបកស្រាយភាគច្រើនចំពោះពាក្យ ប្រជាជនស៊ីវិល នៅក្នុងយុត្តិសាស្ត្រក្រោយឆ្នាំ ១៩៧៥៖ លក្ខណាវិនិច្ឆ័យនៃច្បាប់មនុស្សធម៌អន្តរជាតិ*

46. អ.ជ.ត.ក និង អង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក បានបកស្រាយពីលក្ខខណ្ឌតម្រូវនៃប្រជាជនស៊ីវិល ស្របទៅនឹងមតិភាគច្រើននៅក្នុងករណាយុត្តិសាស្ត្រនៃតុលាការ *មិនអចិន្ត្រៃយ៍*។ មកដល់សព្វថ្ងៃនេះ និយមន័យដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយគឺ និយមន័យ

ដែលកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Blaškić* នៅតុលាការ ICTY ដែលសន្និដ្ឋានថា សមាជិកកងកម្លាំងប្រដាប់អាវុធ ឈ្លប កងស្ម័គ្រចិត្ត និងសមាជិកក្រុមតស៊ូ មិនអាចចាត់ទុកជាជនស៊ីវិលទៅតាមគោលបំណងនៃលក្ខខណ្ឌតម្រូវសម្រាប់ប្រជាជនស៊ីវិលទេ ទោះបីនៅពេល *បាត់បង់សមត្ថភាពប្រយុទ្ធ* ក៏ដោយ[91]។

47. ក្នុងការកំណត់និយមន័យនៃពាក្យប្រជាជនស៊ីវិល អង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Blaškić* បានសំអាងទៅលើមាត្រា ៥០(១) នៃពិធីសារបន្ថែម I នៃអនុសញ្ញាណទីក្រុងហ្សឺណែវ ដែលអង្គជំនុំជម្រះយល់ថាឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ[92]។ មាត្រា ៥០(១) កំណត់និយមន័យពាក្យ "ជនស៊ីវិល" និង "ប្រជាជនស៊ីវិល" ជាលក្ខណៈអវិជ្ជមាន ដោយចែងថា៖

> ជនស៊ីវិលគឺជាមនុស្សដែលមិនស្ថិតនៅក្នុងប្រភេទមនុស្សដែលត្រូវបានកំណត់នៅក្នុងមាត្រា ៤ ក (១) (២) (៣) និង (៦) នៃអនុសញ្ញាទីបី និងនៅក្នុងមាត្រា ៤៣ នៃពិធីសារនេះ។ ក្នុងករណីមានការសង្ស័យថា តើមនុស្សជាជនស៊ីវិលនោះ មនុស្សនោះនឹងត្រូវចាត់ទុកថាជាជនស៊ីវិល។

ជាមូលដ្ឋាន មនុស្សដែលបានយោងនៅក្នុងមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបី និងនៅក្នុងមាត្រា ៤៣ នៃពិធីសារបន្ថែម I ខុសពីប្រភេទអ្នកប្រយុទ្ធដែលស្ថិតក្នុងកងកម្លាំងប្រដាប់អាវុធជាប្រចាំ ឈ្លប ឬចលនាតស៊ូ។ ការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Blaškić* ត្រូវបានតុលាការ ICTY យកមកអនុវត្តតាមនៅក្នុងសាលដីកាជាបន្តបន្ទាប់របស់ខ្លួន[93] ហើយត្រូវបានអនុវត្តនាពេលថ្មីៗ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ[94]។

---

[91] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៣៨ *ដកស្រង់ពី* តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A *សាលដីកា* ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ ("សាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Blaškić*") កថាខណ្ឌ ១១០-១១៣។

[92] សាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Blaškić* កថាខណ្ឌ ១១០។

[93] តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សំណុំរឿងលេខ IT-98-29-A *សាលដីកា* ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៤៤; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Martić* សំណុំរឿងលេខ IT-95-11-A *សាលដីកា* ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩១-៣០២; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និង Šlivančanin* សំណុំរឿងលេខ IT-95-13/1-A *សាលដីកា* ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៨-៣៣។

48. នៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា នៅឆ្នាំ ១៩៧៥ ពីរឆ្នាំមុនមានការអនុម័តពិធីសារបន្ថែម I ពុំទាន់មានការកំណត់និយមន័យនៃពាក្យថា ជនស៊ីវិល នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឡើយទេ[95]។ ហេតុនេះ អង្គជំនុំជម្រះបានប្រកាន់យកនូវអ្វីដែលអង្គជំនុំជម្រះចាត់ទុកថាជានិយមន័យធម្មតា ដែលរាប់បញ្ចូលមនុស្សទាំងអស់ដែលពុំមែនជាសមាជិកកងកម្លាំងប្រដាប់អាវុធ ឬជនដែលត្រូវបានទទួលស្គាល់ថាជាអ្នកប្រយុទ្ធ[96]។ ជាសំខាន់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយស្របទៅនឹងនិយមន័យរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្ដី Blaškić* ដោយលើកឡើងថា ទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ* ពុំមានគុណសម្បត្តិជាជនស៊ីវិលទៅតាមគោលបំណងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ទេ ហើយថា និយមន័យធម្មតាដែលអង្គជំនុំជម្រះបានប្រកាន់យក ស្របទៅនឹងនិយមន័យដែលមាននៅក្នុងមាត្រា ៥០(១) នៃពិធីសារបន្ថែម I [97]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ថា ជាការសន្និដ្ឋានរួម "ភ្នាក់ងារអនុវត្តច្បាប់សង្គ្រាមរបស់រដ្ឋមួយ ត្រូវបានចាត់ទុកថាជាជនស៊ីវិល ផ្អែកតាមគោលបំណងនៃច្បាប់មនុស្សធម៌អន្តរជាតិ"[98]។ ភាពសមរម្យនៃការសំអាងទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ក្នុងការបកស្រាយច្បាប់ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងត្រូវយកមកពិភាក្សានៅក្នុងផ្នែក ix ខាងក្រោម។

*៨. ការបកស្រាយម្យ៉ាងទៀតចំពោះពាក្យ ប្រជាជនស៊ីវិល៖ លក្ខណៈវិនិច្ឆ័យនៃស្ថានភាពជាក់លាក់*

49. សាលដីកាព្រហ្មទណ្ឌអន្តរជាតិមួយចំនួនបានធ្វើការបកស្រាយពាក្យ *ប្រជាជនស៊ីវិល* ខុសពីអង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្ដី Blaškić*។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្ដី Blaškić* បានយល់ថា ក្នុងការសម្រេចថាតើ ពួកគេមានគុណសម្បត្តិជាជនស៊ីវិលឬទេនោះ ត្រូវពិចារណាអំពីស្ថានភាពជាក់លាក់របស់ជនរងគ្រោះ នៅពេលមានការប្រព្រឹត្តិបទ

---

[94] តុលាការ ICC *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo* សំណុំរឿងលេខ ICC-01/05-01/08 *សាលដីកាអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ* ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ១៥២។

[95] សាលក្រមក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៨៥។

[96] *ដូចយោងខាងលើ*។

[97] *ដូចយោងខាងលើ* កថាខណ្ឌ ១៨៦។

[98] *ដូចយោងខាងលើ*។

ល្មើស ជាជាង ឋានៈផ្លូវការរបស់ពួកគេ។ អនុវត្តតាមវិធីសាស្ត្រនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា មនុស្ស *ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* មានគុណសម្បត្តិជាជនស៊ីវិល ទៅតាមគោលបំណងនៃធាតុផ្សំទូទៅរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[99]។ សាលក្រមក្នុង *រឿងក្តី Kupreškić* ក៏បានធ្វើសេចក្តីសន្និដ្ឋានដូចគ្នានេះដែរ[100]។ អង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Jelisić* ដែលបានប្រកាន់យកគោលជំហរគាំទ្រដល់ការបកស្រាយទូលំទូលាយចំពោះពាក្យ *ប្រជាជនស៊ីវិល* ដែរនោះ ក៏បានពិចារណាដល់ពាក្យនេះថាសង្កត់ធ្ងន់ *"ទៅលើទិដ្ឋភាពរួមនៃឧក្រិដ្ឋកម្មជាជាងឋានៈរបស់ជនរងគ្រោះ"*[101]។ គួរឲ្យកត់សម្គាល់ *រឿងក្តី Jelisić* ដែលផ្តោតទៅលើចំណុចរួមនៃឧក្រិដ្ឋកម្ម ជាជាងទៅលើឋានៈរបស់ជនរងគ្រោះ ស្របទៅនឹងវិធីសាស្ត្រដែលបានយកមកអនុវត្តនៅក្នុងការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទី ២ ដែលត្រូវបានលើកមកពិនិត្យនៅក្នុងផ្នែក vi ខាងលើ[102]។

50. ទោះបីអង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Blaškić* បានបដិសេធការបកស្រាយនេះក៏ដោយ តែមានសាលក្រម/សាលដីកាមួយចំនួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") រួមទាំងសាលក្រម/សាលដីកានានាដែលចេញក្រោយសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Blaškić* បានអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃស្ថានភាពជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងក្នុង *រឿងក្តី Blaškić* បានពន្យល់លម្អិត[103] ដែរ។

---

[99] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-T *សាលក្រម* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៤។

[100] តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreškić* សំណុំរឿងលេខ IT-95-16-T *សាលក្រម* ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៧-៥៤៩។

[101] តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-T *សាលក្រម* ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។

[102] *សូមមើលផងដែរ* Rosa Ana Alija Fernández & Jaume Saura Estapá, "Towards a Single and Comprehensive Notion of 'Civilian Population' in Crimes against Humanity", *International Criminal Law Review* ឆ្នាំ ២០១៦ ទំព័រ ១៣-១៤។

[103] តុលាការ ICTR *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T *សាលក្រម* ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bisengimana* សំណុំរឿងលេខ ICTR-00-60-T *សាលក្រម* ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៨-៥១; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Muvunyi* សំណុំរឿងលេខ ICTR-2000-55A-T *សាលក្រម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៥១៣; *រឿងក្តី*

*៩. ការសំអាងលើច្បាប់មនុស្សធម៌អន្តរជាតិដើម្បីបកស្រាយច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

51. ការបកស្រាយពាក្យប្រជាជនស៊ីវិល ដែលអង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Blaškić* បានពន្យល់លម្អិត ហើយអង្គជំនុំជម្រះនៅ អ.វ.ត.ក បានយកមកអនុវត្តនៅក្នុងសំណុំរឿង ០០២ នោះ គឺផ្អែកទៅលើអត្ថន័យនៃពាក្យប្រជាជនស៊ីវិល នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ[104] ។ មាត្រា ៥០(១) នៃពិធីសារបន្ថែម I គឺជាបទប្បញ្ញត្តិគន្លឹះមួយនៅក្នុងវិធានទូទៅជាច្រើន ដែលត្រូវបានតាក់តែងឡើងដើម្បីគ្រប់គ្រងទៅលើការប្រព្រឹត្តិអំពើប្រទូស្តរាយប្រដាប់អាវុធ រវាងកងកម្លាំងបដិបក្ខ។ និយមន័យនេះអាចអនុវត្តបាន និងមានទំនាក់ទំនងតែចំពោះគោលការណ៍នៃភាពដាច់ស្រឡះពីគ្នាប៉ុណ្ណោះ ដែលជាគោលការណ៍គ្រឹះរបស់ច្បាប់មនុស្សធម៌អន្តរជាតិ និងជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានកំណត់ថា ជានិច្ចកាល ភាគីជម្លោះត្រូវចែកឲ្យដាច់ស្រឡះពីគ្នារវាងជនស៊ីវិល និងអ្នកប្រយុទ្ធ ហើយថា ការវាយប្រហារអាចថាមានគោលដៅផ្ទាល់តែទៅលើអ្នកប្រយុទ្ធប៉ុណ្ណោះ មិនមែនទៅលើជនស៊ីវិលទេ[105]។ ហេតុនេះ មុខងាររបស់មាត្រា ៥០(១) គឺការកំណត់ប្រភេទជាអ្នកប្រយុទ្ធ ឬ ជនស៊ីវិល ដែលបុគ្គលស្ថិតក្នុង នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ។

52. ដូចបានឃើញខាងលើ មាត្រា ៥០(១) កំណត់និយមន័យពាក្យ ជនស៊ីវិល និងប្រជាជនស៊ីវិល ជាលក្ខណៈអវិជ្ជមាន ដោយចែងថា ជនស៊ីវិលជាមនុស្សដែលមិនស្ថិតក្នុងកងកម្លាំង ឬក្រុមប្រដាប់អាវុធជាផ្លូវការ ឬមិនផ្លូវការ។ ទោះជាយ៉ាងណាក្តី ប្រភេទនានាដែលបានលើកឡើងក្នុងមាត្រា ៥០(១) បានសន្មតជាមុនអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ (ទោះមានលក្ខណៈជាតិក្តី ឬអន្តរជាតិក្តី វាពុំពាក់ព័ន្ធទៅនឹងការពិភាក្សានេះទេ)។ នៅក្នុងការសម្រេចយោងទៅមាត្រា ៥០(១) អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Blaškić* បានសំអាងលើរបាយការណ៍

---

*រដ្ឋអាជ្ញា តទល់នឹង Bagilishema* សំណុំរឿងលេខ ICTR-95-1A-T *សាលក្រម* ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៧៩។

[104] *សូមមើល* សាលដីកាលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Blaškić* កថាខណ្ឌ ១១០-១១៣។

[105] *សូមមើល* ICRC វិធាន ១៖ គោលការណ៍នៃការបែងចែកដាច់ពីគ្នារវាងជនស៊ីវិល និង អ្នកប្រយុទ្ធ នៅក្នុង *មូលដ្ឋានទិន្នន័យច្បាប់ទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ* អាចរកបាននៅលើគេហទំព័រ៖ https://ihl-databases.icrc.org/customary-ihl/eng/docs/v1_cha_chapter1_rule1។

របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ *ក្នុងចំណោមឯកសារផ្សេងទៀត* ដែលបានកំណត់ថា អនុសញ្ញាទីក្រុងហ្សឺណែវគឺជាលិខិតុបករណ៍ដែលចែងអំពី "*មូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់ដែលអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ*"[106]។ ទោះជាយ៉ាងណាក្តី តាមការវិភាគបឋម សំអាងហេតុនេះផ្ទាល់ធ្វើឱ្យមាត្រា ៥០(១) ពុំសក្តិសមចំពោះការកំណត់និយមន័យពាក្យប្រជាជនស៊ីវិល ទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមិនពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធដែលកំពុងបន្ត។ ដូចបានអង្គជំនុំជម្រះសាលាដំបូងមួយនៃតុលាការ ICTR បានធ្វើការកត់សម្គាល់ប្រហែល ៥ ឆ្នាំមុនចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Blaškić* ថា ជាយូរមកហើយ និយមន័យផ្លូវច្បាប់នៃពាក្យ *ជនស៊ីវិល* និង *ប្រជាជនស៊ីវិល* ត្រូវបានយកមកពិភាក្សានៅក្នុងបរិបទជម្លោះប្រដាប់អាវុធ ហេតុនេះហើយ និយមន័យនេះតែងតែត្រូវបានពិនិត្យនៅក្នុងបរិបទនៃកងកម្លាំងបដិបក្ខ។ ទោះជាយ៉ាងណាក្តី ដោយពិចារណាឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងទាំងនៅក្នុង និងក្រៅបរិបទនៃជម្លោះប្រដាប់អាវុធនោះ ពាក្យទាំងពីរនេះគួរចាំបាច់ត្រូវយល់ឱ្យស្របគ្នាទាំងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធផង និងពុំមានជម្លោះប្រដាប់អាវុធផង[107]។

53. គេអាចយល់បានចំពោះការពឹងផ្អែកទៅលើនិយមន័យនៃប្រជាជនស៊ីវិលនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិរបស់តុលាការ ICTY ដោយហេតុថា យុត្តាធិការរបស់តុលាការនេះត្រូវបានកម្រិតត្រឹមតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធប៉ុណ្ណោះ[108]។ តាមពិត អង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Kunarac* បានកត់សម្គាល់ថា "*វិសាលភាពដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តក្នុងអំឡុងមានជម្លោះប្រដាប់អាវុធ ច្បាប់សង្គ្រាម ផ្តល់ជាបទដ្ឋានមួយដែលអង្គជំនុំជម្រះអាចវាយតម្លៃពីលក្ខណៈនៃការវាយប្រហារ និងនីត្យានុកូលភាពនៃអំពើដែលបានប្រព្រឹត្តនៅក្នុងការវាយ*

---

[106] សាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Blaškić* កថាខណ្ឌ ១១០។

[107] *សូមមើល* តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-T *សាលដីកា* ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧។

[108] លក្ខន្តិកៈតុលាការ ICTY មាត្រា ៥។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A *សាលដីកា* ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២៤៩; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šešelj* សំណុំរឿងលេខ IT-03-67-AR72.1 *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងយុត្តាធិការ* ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ កថាខណ្ឌ ១២-១៣។

*ប្រហារនោះ"*[109]។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Taylor* នៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ក៏បានបង្ហាញពីការពិចារណាស្រដៀងគ្នានេះដែរ[110]។ ហេតុនេះពុំមានអ្វីភ្ញាក់ផ្អើលទេដែលថា នៅតុលាការ ICTR ដែលពុំមានលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ អង្គជំនុំជម្រះមួយចំនួនបានសម្រេចមិនអនុវត្តតាមនិយមន័យពាក្យ *ប្រជាជនស៊ីវិល* នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី* *Blaškić* បានប្រកាន់យកឡើយ[111]។

54. មានការសន្និដ្ឋានរួមគ្នានៅក្នុងយុត្តិសាស្ត្រនៃព្រហ្មទណ្ឌអន្តរជាតិថា *ការវាយប្រហារជាលក្ខណៈទូទៅ ឬជាប្រព័ន្ធ* ទៅលើ*ប្រជាជនស៊ីវិល* ពុំចាំបាច់ជាការវាយប្រហារផ្នែកយោធាក្នុងន័យជាយូរមកហើយនោះទេ តែត្រូវមាន *"ការធ្វើបាបប្រជាជនស៊ីវិល"*[112]។ នេះជាទស្សនៈដោយឡែកខុសពីទស្សនៈនៃជម្លោះប្រដាប់អាវុធ[113]។ មានការសង្កេតដោយសមរម្យថា ប្រសិនបើទស្សនៈនៃ "ការវាយប្រហារ" នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ មិនត្រូវបានប្រើប្រាស់ក្នុងការកំណត់និយមន័យនៃពាក្យដូចគ្នានៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ វាពុំមានភាពច្បាស់លាស់ពីមូលហេតុនៃការយកនិយមន័យនៃពាក្យប្រជាជនស៊ីវិលនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិមកអនុវត្តដោយស្វ័យប្រវត្តិចំពោះច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[114]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី* *Tadić* នៅក្នុងតុលាការ ICTY

---

[109] តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23/1-A *សាលដីកា* ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ("សាលដីកាលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Kunarac*") កថាខណ្ឌ ៩១។

[110] តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-T *សាលក្រម* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៥១០។

[111] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bisengimana* សាលក្រម អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTR (ICTR-00-60-T) ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៨-៥១; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Muvunyi*, សាលក្រម អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ ICTR (ICTR-2000-55A-T) ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៥១៣។

[112] សាលក្រមក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៧៨ *ដកស្រង់ពី* សាលដីកាលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Kunarac* កថាខណ្ឌ ៨៦។

[113] *ដូចយោងខាងលើ* កថាខណ្ឌ ១៧៨។

[114] Leila Nadya Sadat, "Putting Peacetime First: Crimes against Humanity and the Civilian Population Requirement", *Emory International Law Review*, Vol. 31(2), ឆ្នាំ ២០១៧ ទំព័រ ២៥៣។

បានកត់សម្គាល់រួចមកហើយថា និយមន័យនៃពាក្យជនស៊ីវិលនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ *"មិនអាចអនុវត្តភ្លាមៗចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ដោយសារវាជាផ្នែកនៃច្បាប់សង្គ្រាម ឬទំនៀមទម្លាប់សង្គ្រាម ហើយអាចយកមកអនុវត្តបានតែតាមរយៈការប្រៀបធៀបប៉ុណ្ណោះ"*[115]។

*១០. ការបកស្រាយពាក្យ ប្រជាជនស៊ីវិល ទៅតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

55. ក្នុងសេចក្តីអធិប្បាយស្តីពីសេចក្តីព្រាងពិធីសារបន្ថែមរបស់អនុសញ្ញាទីក្រុងហ្សឺណែវ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ("ICRC") បានគាំទ្រ "និយមន័យបែបទូលំទូលាយ" នៃជនស៊ីវិល ដែលគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិយល់ឃើញថាមានយុត្តិកម្ម *"ទៅតាមគោលបំណងដែលមាន ដែលជាការការពារជាទូទៅប្រឆាំងនឹងផលប៉ះពាល់នៃភាពប្រទូស្តរាយ"*[116]។ នៅក្នុងផ្នែក គ ខាងលើ បន្ទាប់ពីពិនិត្យទៅលើរបាយការណ៍ និងយុត្តិសាស្ត្រស្តីពីគោលបំណងនៃច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យើងបានសន្និដ្ឋានថា វាអាចត្រូវបានចាត់ទុកថាជាការការពារប្រឆាំងនឹងការរំលោភបំពានទៅលើសិទ្ធិមនុស្សដែលបានប្រព្រឹត្តជាទ្រង់ទ្រាយធំ ប្រឆាំងនឹងបុគ្គលនានា រួមទាំងប្រជាជនរបស់រដ្ឋខ្លួនឯងផ្ទាល់ ដែលពុំត្រូវបានការពារដោយច្បាប់ និងទំនៀមទម្លាប់សង្គ្រាមដែលមានស្រាប់។ ហេតុនេះ យើងជឿជាក់ថា ក្នុងការបកស្រាយច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឲ្យស្របទៅនឹងកម្មវត្ថុ និងគោលបំណងនៅក្នុងសេណារីយ៉ូមួយដែលត្រូវបានប្រមើលទុកជាមុននៅក្នុងបញ្ហានេះ ត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យនៃស្ថានភាពជាក់លាក់ ពុំមែនលក្ខណវិនិច្ឆ័យនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិទេ (សូមមើល

---

[115] តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T *ទស្សនៈ និង សាលដីកា* ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៣៩។

[116] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, *សេចក្តីព្រាងពិធីសារបន្ថែមរបស់អនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩៖ សេចក្តីអធិប្បាយ* ក្រុងហ្សឺណែវ ខែ តុលា ឆ្នាំ ១៩៧៣ ទំព័រ ៥៥។

ផ្នែក ix ខាងលើ)។ ហេតុនេះ គេត្រូវប្រកាន់យកនិយមន័យនៃពាក្យប្រជាជនស៊ីវិលតាមន័យទូលាយ ដែលសំដៅដល់ប្រជាជនទាំងមូលនៅក្នុងប្រទេសណាមួយ[117]។

56. ផ្អែកលើមូលដ្ឋាននេះ យើងយល់ឃើញថា ជាគោលការណ៍ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋមួយ ឬអង្គការមួយ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដែលបានធ្វើឡើងនៅពេលមានសន្តិភាព បានបំពេញទៅតាមលក្ខខណ្ឌទូទៅនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល តាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក។

57. ជាគោលការណ៍ ការវាយប្រហារដែលបានធ្វើឡើងដោយរដ្ឋ ឬរបបមួយ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ក៏បានបំពេញទៅតាមលក្ខខណ្ឌទូទៅដែរ បើសិនជាកងកម្លាំងប្រដាប់អាវុធដែលរងការវាយប្រហារពិតជាមានសម្ព័ន្ធភាព ឬបានផ្តល់ជំនួយពាក់ព័ន្ធនឹងវិស័យយោធាដល់ក្រុមប្រឆាំងនៅក្នុងជម្លោះ។ នៅក្នុងសេណារីយ៉ូនេះ កងកម្លាំងប្រដាប់អាវុធដែលត្រូវបានកំណត់ជាគោលដៅ មិនអាចត្រូវបានចាត់ទុកថាជាជនស៊ីវិលទេ និងពុំបានបំពេញតាមលក្ខខណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលពាក់ព័ន្ធទេ[118]។

58. គោលការណ៍នីត្យានុកូលភាពពុំត្រូវបានបំពារបំពានដោយសេចក្តីសន្និដ្ឋាននេះទេ ដោយផ្អែកលើសំអាងហេតុជាច្រើន។

59. ទីមួយ យុត្តិសាស្ត្រមុនឆ្នាំ ១៩៧៥ ដែលបានពិនិត្យខាងលើនៅក្នុងផ្នែក vi មិនបានបកស្រាយពាក្យប្រជាជនស៊ីវិល ដោយយោងដល់ច្បាប់មនុស្សធម៌អន្តរជាតិទេ។ ផ្ទុយទៅវិញ វាបានផ្តោតទៅលើលក្ខណៈជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្ម និងទៅលើលក្ខណៈរួមនៃឧក្រិដ្ឋកម្មទាំងនោះ ដោយពុំបានចោទសួរអំពីសមាសភាពនៃក្រុមជនរងគ្រោះដែលទទួលការធ្វើបាប

---

[117] សារណារបស់ Ben Saul កថាខណ្ឌ ៣(គ)-(ឃ), ១៨-១៩ ដកស្រង់ពី *Dictionnaire de l'Académie française* (ការបោះពុម្ពលើកទី ៩) ទៅលើអ៊ីនធឺណេត។

[118] ស្រដៀងគ្នាដែរ ឧទាហរណ៍ Kai Ambos, Treatise on International Criminal Law, Vol. II, (OUP), ឆ្នាំ ២០១៤ ទំព័រ ៦៦ ច. – ដូចបានលើកឡើងនៅក្នុងបរិបទនេះថា ពាក់ព័ន្ធនឹងចារី ការពិត ការទទួលខុសត្រូវអាចដកចេញពីទិដ្ឋភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាបញ្ហានៃចេតនាឧក្រិដ្ឋ ពាក់ព័ន្ធនឹងធាតុផ្សំទូទៅ ប្រសិនបើនៅក្នុងវិសាលភាពដែលថា ចារីនៃឧក្រិដ្ឋកម្មជាក់ស្តែងមានជំនឿដោយមិនត្រឹមត្រូវថា មានសម្ព័ន្ធភាពនេះ ឬ ផ្តល់ការគាំទ្រ។

ពីរដ្ឋទេ។ តាមពិត តុលាការបានលើកឡើងយ៉ាងច្បាស់ថា ច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានការពារ "*ជនណាដែលពួកគេមិនពេញចិត្ត*"[119] ឬ "*មនុស្សធម៌*" ដែលពិបាកក្នុងការធ្វើឱ្យស្របទៅនឹងការបកស្រាយដែលដកកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋចេញពីការការពារប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[120]។ ការបកស្រាយពាក្យប្រជាជនស៊ីវិលដែលផ្អែកលើច្បាប់មនុស្សធម៌អន្តរជាតិ ក្លាយជាគោលជំហរភាគច្រើនតែ *បន្ទាប់ពី* ពេលវេលាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ប៉ុណ្ណោះ។ ទាក់ទិននឹងចំណុចនេះ យើងយល់ឃើញថា ការបកស្រាយពាក្យប្រជាជនស៊ីវិល ដោយផ្អែកលើច្បាប់មនុស្សធម៌អន្តរជាតិ បង្ហាញពីករណីនៃការណែនាំច្បាប់ប្រឆាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានភាពអត់ឱនជាង ដែលតម្រូវឱ្យអនុវត្តច្បាប់ដាក់ទោសស្រាលជាងមុន *(lex mitior)*។ គោលការណ៍នេះពាក់ព័ន្ធនឹងការបញ្ចូលទោសទណ្ឌដែលមានភាពអត់ឱនជាងមុន ទាក់ទិននឹងបទល្មើសមួយចំនួន ឬការមិនចាត់ទុកជាបទល្មើសមួយផ្នែក ឬទាំងស្រុង[121] ដែលនៅក្នុងករណីនេះ យើងពិភាក្សាអំពីការបកស្រាយផ្សេងនៅក្នុងបរិបទនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលមិនសក្តិសមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពុំមានទំនាក់ទំនងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ទៅតាមសំអាងហេតុដែលបានពន្យល់ខាងលើ។

60. ទីពីរ ដោយពិនិត្យទៅលើឯកសារដែលអាចរកបាននៅពេលនោះ និងដែលត្រូវបានយកមកសំអាងនៅក្នុងការវិភាគនេះ និងក្នុងករណីចាំបាច់ត្រូវមានជំនួយពីអ្នកប្រឹក្សាផ្នែកច្បាប់នោះ គេអាចប្រមើលមើលបានថា នៅឆ្នាំ ១៩៧៥ ការប្រព្រឹត្តិអំពើរំលោភបំពានសិទ្ធិមនុស្សជាទ្រង់ទ្រាយធំដោយរដ្ឋមកលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចបណ្តាលឱ្យចារីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលបាន។ ក្នុងករណីណាក៏ដោយ ពុំតម្រូវឱ្យជនល្មើសត្រូវ

---

[119] *រឿងក្តី H* ទំព័រ ២៣៤ លេខ ២៦។

[120] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅតុលាការយោធា Nueremberg តាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង Nuernberg ខែ តុលា ឆ្នាំ ១៩៤៦ - ខែ មេសា ឆ្នាំ ១៩៤៩ Vol. IV *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Otto Ohlendorf និងអ្នកផ្សេងទៀត* ទំព័រ ៤៩៧។

[121] តុលាការ ECtHR, *រឿងក្តី Scoppola តទល់នឹង ប្រទេសអ៊ីតាលី (លេខ ២)* ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ១០៣-១០៩។

ប្រមើលមើលឃើញពីប្រភេទនៃបទល្មើសច្បាស់លាស់ចំពោះការប្រព្រឹត្តិរបស់គាត់ ឬថាតើវាជាឧក្រិដ្ឋកម្មតាមច្បាប់ជាតិ ឬអន្តរជាតិនោះទេ[122]។

61. លក្ខណៈឧក្រិដ្ឋនៃការវាយប្រហារ ដូចជា ការវាយប្រហារដែលបានប្រមើលមើលទុកនៅក្នុងបញ្ហានេះ ក៏អាចព្យាករជាមុនបានដោយសមហេតុផល និងពេញលេញនៅក្នុងឆ្នាំ ១៩៧៥ បានដែរ តាមរយៈអត្ថិភាពនៃអនុសញ្ញានានាស្តីពីសិទ្ធិមនុស្ស ដូចជា សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាអន្តរជាតិ ស្តីពិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលផ្តល់ការការពារជាសាកលពាក់ព័ន្ធនឹងសិទ្ធិជាសារវ័ន្តដែលត្រូវបានការពារដោយច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[123]។ ពាក់ព័ន្ធនឹងបញ្ហានេះ យើងកត់សម្គាល់ពីការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារក្តី មាស មុត ថា ច្បាប់សិទ្ធិមនុស្សពុំមែនជាច្បាប់ព្រហ្មទណ្ឌទេ ហេតុនេះ មិនអាចយកមកប្រើដើម្បីបកស្រាយអំពីបទប្បញ្ញត្តិផ្នែកព្រហ្មទណ្ឌបានទេ[124]។ប្រសិនបើលើកឡើងទៅតាមការអះអាងបែបទូលំទូលាយ និងពេញលេញ ទស្សនៈនេះពុំត្រឹមត្រូវទេ។ ការរំលោភបំពានសិទ្ធិមនុស្សផ្តល់ព័ត៌មានដោយផ្ទាល់ទៅខ្លឹមសារនៃបទប្បញ្ញត្តិផ្នែកព្រហ្មទណ្ឌដែលគ្រាន់តែផ្តល់ការផ្តន្ទាទោសចំពោះការរំលោភបំពាន។ អំណះអំណាងរបស់មេធាវីការពារក្តី មាស មុត ត្រឹមត្រូវ ដោយរាល់ការរំលោភបំពានទៅលើសិទ្ធិមនុស្សទាំងអស់មិនចាំបាច់សុទ្ធតែមានការទទួលខុសត្រូវព្រហ្មទណ្ឌនៅកម្រិតអន្តរជាតិ ឬជាតិនោះទេ។ ដោយក្តីគោរព បញ្ហានេះមិនមែនជាបញ្ហាសំខាន់នៅទីនេះទេ។ ដូចបានឃើញខាងលើ មាត្រា ៥០(១) នៃពិធីសារបន្ថែម I ត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីបកស្រាយពីពាក្យប្រជាជនស៊ីវិលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មាត្រា ៥០(១) ក៏ពុំមែនជាបទប្បញ្ញត្តិផ្នែកព្រហ្មទណ្ឌដែរ [125]។

---

[122] តុលាការ ECtHR *រឿងក្តី S.W. តទល់នឹង* ចក្រភពអង់គ្លេស ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៥-៣៦។

[123] សេចក្តីសន្និដ្ឋានរបស់ ស.ព.អ កថាខណ្ឌ ១០។

[124] ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២២។

[125] ចំពោះនិន្នាការលេចឡើង ដើម្បីស្នើសុំការណែនាំស្តីអំពីយុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សក្នុងការកំណត់និយមន័យ *ក្នុងចំណោមប្រការផ្សេងទៀត* ការរំលោភសិទ្ធិមនុស្សដែលសំដៅដល់ឧក្រិដ្ឋកម្មអន្តរជាតិ *សូមមើល* Annika Jones, "Insights Into an Emerging Relationship: Use of Human Rights Jurisprudence at the International Criminal Court", *Human Rights Law Review*, ឆ្នាំ ២០១៦ ទំព័រ ១៦៧០១ ,-៧២៩។

62. ជាងនេះទៀត ដូចបានកត់សម្គាល់នៅក្នុងផ្នែក vi ខាងលើ អនុសញ្ញាស្តីពីអាប៉ាថេត និង អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ក៏បានលើកឡើងពីការបំពេញលក្ខខណ្ឌតម្រូវស្តីពីភាពអាចប្រមើលមើលបានដែរពាក់ព័ន្ធនឹងបញ្ហានេះ។

63. ទីបី ការដកកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋចេញពីការការពារប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងរារាំងដល់គោលបំណងរបស់ច្បាប់ និងបណ្តាលឲ្យមានលទ្ធផលដែលមិនសមហេតុផល។ វានឹងដកការការពារដល់ពលរដ្ឋដែលរងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់រដ្ឋមួយ ដែលមិនបានចូលរួមក្នុងភាពប្រទូស្តរាយ តែទទួលបានសិទ្ធិមនុស្សដូចគ្នានឹងមនុស្សដែលទទួលការការពារពីអាជ្ញាធរសាធារណៈផ្សេងទៀតរបស់រដ្ឋនោះដែរ។ ជាបញ្ហានោះគឺថា ចំពោះទាហានផ្ទាល់របស់រដ្ឋ ការបែងចែកដាច់ពីគ្នានៅក្នុងច្បាប់មនុស្សធម៌អន្តជាតិដោយផ្អែកលើឋានៈជាអ្នកប្រយុទ្ធ ពុំមានហេតុផលទាល់តែសោះ។ តាមពិតទៅ សូម្បីតែនៅក្នុងបរិបទនៃច្បាប់មនុស្សធម៌អន្តរជាតិក៏ដោយ ជនស៊ីវិលបាត់បង់ឋានៈរបស់ខ្លួនជាជនស៊ីវិល ទៅតាមគោលបំណងនៃការការពារក្រោមបទប្បញ្ញត្តិនៃឧក្រិដ្ឋកម្មសង្គ្រាម នៅពេលពួកគេកាន់អាវុធ និងចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធជាប្រចាំ ពួកគេក្លាយជាគោលដៅស្របច្បាប់។ ហេតុនេះ និយមន័យនៃជនស៊ីវិល និងអ្នកប្រយុទ្ធ ដែលមិនច្បាស់ ដោយផ្អែកទៅលើឋានៈនោះដោយពុំលើកឡើងពីសកម្មភាពជាក់ស្តែងរបស់ពួកគេ ពុំផ្ទុះបញ្ចាំងការពិតជាក់ស្តែង សូម្បីនៅក្នុងសេណារីយ៉ូនៃប្រជាជនជាសត្រូវដែលមានការទទួលស្គាល់ច្រើនក៏ដោយ។ ការបកស្រាយចាំបាច់ត្រូវសម្លឹងមើលគោលដៅ និងគោលបំណងនៃការការពារដែលមានចែងនៅក្នុងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើសិនជាពុំមានការអនុវត្តច្បាស់លាស់របស់រដ្ឋ។ ដូចបានពន្យល់ខាងលើ ការអនុវត្តបែបនេះមិនត្រូវបានរកឃើញសម្រាប់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក នោះទេ។

64. ដូចមេធាវីការពារក្តី មាស មុត បានជំទាស់ ដោយយោងទៅលើទឡ្ហីករណ៍ដែល Cassese បានលើកឡើង វាហាក់ដូចជាពុំមានភាពប្រាកដនិយមផងដែរដែល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តទៅលើទាហានផ្ទាល់របស់រដ្ឋគួរតែស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការយោធារបស់រដ្ឋដែលវាយប្រហារនោះ[126]។ ករណីនេះអាចសមហេតុផល ក្នុងករណីដែល

[126] ចម្លើយតបរបស់ មាស មុត លេខ ១៣។

ឧក្រិដ្ឋកម្មដាច់តែឯង ពុំមានលក្ខណៈជាប្រព័ន្ធដែលបានប្រព្រឹត្តដោយមន្ត្រី ឬមន្ត្រីរបស់រដ្ឋដែលទុច្ចរិត។ ទោះជាយ៉ាងណាក្តី ក្នុងកាលៈទេសៈដែលមានការវាយប្រហារជាប្រព័ន្ធ ឬជាទូទៅ ដែលជាផ្នែកសំខាន់នៃគោលនយោបាយរបស់រដ្ឋ ឬរបបនោះ[127] ទទ្បីករណ៍ដែលមេធាវីការពារក្តីបានលើកឡើងដូចនឹងការរំពឹងថា រដ្ឋនឹងធ្វើទុក្ខបុកម្នេញចំពោះមន្ត្រីរបស់ខ្លួនជាមុន ហើយបន្ទាប់មកផ្តន្ទាទោសរដ្ឋខ្លួនចំពោះការវាយប្រហារនោះ។

65. លើសពីនេះទៀត ពុំមានយុត្តិកម្មដែលនឹងណែនាំ ឬអនុញ្ញាតឲ្យមានការប្រព្រឹត្តិផ្សេងគ្នាចំពោះទាហានផ្ទាល់របស់របបមួយ ដោយសារតែឋានៈការងារផ្លូវការរបស់ពួកគេទេ។ ឧទាហរណ៍មួយគឺគ្រប់គ្រាន់ក្នុងការបង្ហាញថា ទស្សនៈនេះពុំមានហេតុផលទេ។ ឧទាហរណ៍ថា មានការផ្លាស់ប្តូររដ្ឋាភិបាលក្នុងពេលសន្តិភាព ជំនួសដោយរដ្ឋបាលថ្មីមួយដែលមានជំហរម៉ឺងម៉ាត់ថា សមាជិកកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនដែលស្ថិតនៅក្នុងសាសនាមួយពុំអាចទុកចិត្តបាន និងមិនសក្តិសមក្នុងការការពារផលប្រយោជន៍របស់រដ្ឋទេ។ រដ្ឋាភិបាលបញ្ជាឲ្យដាក់ពន្ធនាគារសួរចម្លើយដោយធ្វើទារុណកម្ម និងសម្លាប់មន្ត្រីទាំងអស់ដែលស្ថិតក្នុងសាសនានោះ។ ដោយគិតពីគោលបំណង និង គោលដៅរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តើឋានៈការងាររបស់ពួកគេជាទាហានធ្វើឲ្យពួកគេមិនស្ថិតក្នុងការការពារពីច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយរបៀបណា? តាមពិត ប្រសិនបើរដ្ឋាភិបាលអនុវត្តគោលនយោបាយដដែលនេះប្រឆាំងនឹងសមាជិកផ្នែកស៊ើបការណ៍សម្ងាត់របស់ខ្លួន ដែលតាមឋានៈ ជាជនស៊ីវិលពិតប្រាកដ តែទោះជាយ៉ាងណា បានចូលរួមក្នុងការប្រមូលទិន្នន័យដែលអាចត្រូវបានយកមកប្រើប្រាស់ក្នុងគោលបំណងផ្នែកយោធា តើវាមានភាពខុសគ្នាអ្វីខ្លះ? បើតាមដំណោះស្រាយចំពោះបញ្ហានេះដែលមេធាវីការពារក្តី យឹម ទិត្យ តា អាន និង មាស មុត ស្នើឡើងគឺត្រូវការពារសមាជិកប្រដាប់អាវុធនៃកងកម្លាំងនគរបាលប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[128] តែមិនមែន

---

[127] ទោះបី នេះជាកាលៈទេសៈដែលពាក់ព័ន្ធទៅនឹងដំណោះស្រាយបញ្ហាក៏ដោយ តែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំតម្រូវក្នុងចំណោមធាតុផ្សំរបស់វា ថា ការវាយប្រហារជាលក្ខណៈទូទៅ ឬជាប្រព័ន្ធ គឺជាផ្នែកនៃគោលនយោបាយរបស់រដ្ឋទេ។ *សូមមើល* សំណុំរឿងលេខ ០០២/១១-E313 *សាលក្រមក្នុងសំណុំរឿង ០០២/១* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨១។

[128] សាលក្រមក្នុងសំណុំរឿង ០០២/១ កថាខណ្ឌ ១៨៥-១៨៦។

ការពារសមាជិកកងទ័ពរបស់រដ្ឋទេ ដោយមិនគិតថា តើពួកគេបាន ឬមិនបាន កាន់អាវុធដែលជាផ្នែកមួយនៃភារកិច្ចប្រចាំថ្ងៃរបស់ពួកគេទេ។

66. ច្បាប់ទំនៀមទម្លាប់អន្តរជាតិក្រោយ Nuremberg មិនគួរយកមកបកស្រាយថាជាទទួលស្គាល់ថា រដ្ឋមានសិទ្ធិអនុវត្តដោយលើកលែងដោយអត្តនោម័តពីគោលបំណងនៃច្បាប់នោះទេ។ និយាយម្យ៉ាងទៀត ក្រោយ Nuremberg រដ្ឋលែងទទួលបានការអនុញ្ញាតឲ្យជ្រើសរើសតាមអំពើចិត្តនូវការកម្រិត និងការទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់ខ្លួនទៅលើបុគ្គលនានាទៀតហើយ។ ការដែលរដ្ឋម្តងម្កាលធ្វើបែបនេះដោយសំអាងទៅលើអធិបតេយ្យភាព គឺជាការបង្ហាញអំណាច ពុំមែនជាយុត្តិធម៌ទេ។ ចំណុចនេះមានភាពច្បាស់លាស់រួចហើយនៅឆ្នាំ១៩៧៥។ ទោះបីវាអាចមានភាពសមរម្យចំពោះទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ ដែលទទួលស្គាល់អធិបតេយ្យភាពថាមានតម្លៃកំពូលក៏ដោយ តែទឡ្ហីករណ៍នេះមិនពាក់ព័ន្ធទៅនឹងបរិបទនៃច្បាប់ព្រហ្មទណ្ឌដែលទាក់ទិននឹងការការពារ និងការទទួលខុសត្រូវរបស់មនុស្សទេ ហើយវាកាន់តែពុំមានភាពពាក់ព័ន្ធទៅទៀតនៅក្នុងស្ថានភាពរបស់ អ.វ.ត.ក ជាតុលាការកម្ពុជា ដែលមានកាតព្វកិច្ចស៊ើបអង្កេត និង ក្នុងករណីសមស្រប ជំនុំជម្រះ និងផ្តន្ទាទោសដល់ប្រជាជនកម្ពុជាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរទៅលើប្រជាជនកម្ពុជា។ ច្បាប់ព្រហ្មទណ្ឌគឺជាការបង្ហាញពីការវិនិច្ឆ័យផ្នែកសីលធម៌ចុងក្រោយរបស់សង្គម ទាក់ទិននឹងការប្រព្រឹត្តិមួយចំនួន។ នៅពេលសហគមន៍អន្តរជាតិក្រោយសង្គ្រាមលោកលើកទី ២ បានជ្រើសរើសអនុម័តច្បាប់ព្រហ្មទណ្ឌជាមធ្យោបាយក្នុងការឆ្លើយតបទៅនឹងអ្វីដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌជាតិនាពេលនោះ គេត្រូវគោរពតាមភាពសមស្របរបស់ច្បាប់នោះតាមគោលការណ៍នីតិរដ្ឋ។ ករណីលើកលែងពីការទទួលខុសត្រូវក្រោមប្រព័ន្ធនោះអាចទៅរួច ជាគោលការណ៍ ដូចក្នុងប្រព័ន្ធច្បាប់នានាដែរ តែចាំបាច់ត្រូវផ្អែកលើទឡ្ហីករណ៍ដែលប្រព័ន្ធនោះទទួលយកបាន។ អ្វីផ្សេងទៀតក្រៅពីនេះគ្រាន់តែជាបង្ហាញអំពីអំណាចដោយអត្តនោម័តប៉ុណ្ណោះ។ ការដកទាហានរបស់ខ្លួនចេញពីការការពារដែលមានចែងក្នុងច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើការបកស្រាយតឹងរ៉ឹងចំពោះពាក្យពេចន៍របស់ច្បាប់នោះដែលមេធាវីការពារក្តីកំពុងជំរុញនោះ ពុំមែនជាទឡ្ហីករណ៍ដែលអាចទទួលយកបានទេ ហើយវាកាន់តែពុំសមហេតុផលទៅទៀត នៅពេលដែលករណីលើកលែងនេះផ្អែកតែទៅលើភាពអកម្មផ្នែកប្រវត្តិសាស្ត្រ ដើម្បីដោះស្រាយទៅលើបញ្ហា ជាជាងការបង្ហាញដោយសកម្មភាពអំពី

ការយល់ឃើញខុសគ្នានៅលើឆាកអន្តរជាតិ។ ដូចដែល Oliver Wendell Holmes បានថ្លែង យ៉ាងត្រឹមត្រូវនៅក្នុង*រឿងក្តី Olmstead តទល់នឹង សហរដ្ឋអាមេរិក* ថា “*តុលាការអាចនឹងមានកំហុសដោយងាយ ប្រសិនបើប្រកាន់យកតែពាក្យពេចន៍របស់ច្បាប់ត្រង់ៗពេក ដោយពាក្យពេចន៍ទាំងនោះពាំនាំនូវគោលនយោបាយមួយដែលឆ្ងាយពីអត្ថន័យច្បាប់នោះ*”[129]។

67. គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* ដូចដែល អ.ជ.ត.ក បានបកស្រាយ ពុំបានជំទាស់ទៅនឹងទស្សនៈដែលប្រើនៅទីនេះទេ។ ទីមួយ គោលការណ៍នេះគឺជាលក្ខណវិនិច្ឆ័យបកស្រាយអត្ថន័យដែលមិនសូវសំខាន់ ដែលអនុវត្តតែក្រោយពេលបកស្រាយច្បាប់តាមរយៈលក្ខណវិនិច្ឆ័យសមស្របរួចហើយប៉ុណ្ណោះ រួមទាំងការបកស្រាយតាមន័យចង្អៀតផងដែរ។ ដូចបានឃើញខាងលើ ការបញ្ចូលកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋទៅក្នុងពាក្យប្រជាជនស៊ីវិល ត្រូវបានតម្រូវដោយគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយវាស្របទៅនឹងការបកស្រាយច្បាប់នៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី ២ ផងដែរ។ ហេតុនេះ នៅឆ្នាំ ១៩៧៥ ការប្រព្រឹត្តិដែលបានរៀបរាប់នៅក្នុងបញ្ហានេះ អាចត្រូវបានរំពឹងថា ស្ថិតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដោយសារវាមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះ។

68. ទីពីរ គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* និងការបកស្រាយតាមន័យចង្អៀត ពុំតម្រូវឲ្យប្រកាន់យកទស្សនៈដែលគ្មានហេតុផលទេ។ ដូចដែលការ វិភាគនៅក្នុងសេចក្តីសម្រេចនេះបង្ហាញ ត្រឹមតែឋានៈផ្លូវការរបស់សមាជិកកងកម្លាំងប្រដាប់អាវុធពុំពាក់ព័ន្ធទាល់តែសោះចំពោះទំនាក់ទំនងរបស់ពួកគេទៅនឹងរដ្ឋ ឬរបបផ្ទាល់ របស់ពួកគេទេ ហើយការដកពួកគេចេញពីការការពារតាមច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដាក់ពួកគេឲ្យស្ថិតក្រោមសម្រេចរបស់តុលាការយោធារបស់របបដែលធ្វើឲ្យ

---

[129] *រឿងក្តី Olmstead តទល់នឹង សហរដ្ឋអាមេរិក* 277 U.S. 438, 469 (1928) (Holmes, J., មតិយល់ស្រប និងមតិជំទាស់)។

ពួកគេក្លាយជាជនរងគ្រោះ ពិតជាធ្វើឲ្យច្បាប់ក្លាយជាគំរូមិនល្អនៃ Dicken ដែលថា៖ *[...] លោក Bumble និយាយថា "ប្រសិនបើច្បាប់សន្មតបែបនោះ ច្បាប់នោះគឺជាភាពល្ងង់ខ្លៅ"*[130]។

**ផ្អែកលើសំអាងហេតុនានាដែលបានលើកឡើងខាងលើ យើង៖**

69. **សន្និដ្ឋាន** ថា៖

i. ជាគោលការណ៍ តាមច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានអត្ថិភាពចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន គឺជាការវាយប្រហារទៅលើប្រជាជនស៊ីវិល ទៅតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ អ.វ.ត.ក។ និង

ii. ថា សំអាងហេតុក្នុងផ្នែក i. ខាងលើ មិនអនុវត្ត ពាក់ព័ន្ធនឹងកងកម្លាំងប្រដាប់អាវុធដែលទទួលរងការវាយប្រហារ តាមពិត មានសម្ព័ន្ធភាព ឬ ផ្តល់ការគាំទ្រពាក់ព័ន្ធ ទៅខាងកងទ័ពប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធទេ។

សេចក្តីជូនដំណឹងនេះត្រូវដាក់ជាភាសាអង់គ្លេស ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនជាក្រោយ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co-Investigating Judge
Co-juge d'instruction international

---

[130] Charles Dickens, *Oliver Twist*, (Richard Bentley, London) 2nd Edition in 3 Volumes, vol. III, ឆ្នាំ ១៨៣៩ ទំព័រ ២៧៩។